១៤គ្រួសារប៉ុណ្ណោះ និងមានប្រជាជនសរុបចំនួន១០២ ស្ត្រីមានពាក់កណ្តាលនៃចំនួនប្រជាជនសរុបគឺ៥២នាក់។ ចំណែកឯក្នុងឃុំតាឡាត ចំនួនប្រជាជននៃភូមិទាំងពីរខុសគ្នាជាងពាក់កណ្តាល៖ ភូមិពែត់មាន៧៦គ្រួសារ និងមានប្រជាជនសរុប៣៣០នាក់ ដែលក្នុងនោះស្ត្រីមាន១៧១នាក់ និងភូមិតាឡាតមាន១៥០គ្រួសារ មានប្រជាជនរស់នៅរហូតដល់៦៦០នាក់ និងមានកស្ត្រីចំនួន៣២៣នាក់។ ក្រាហ្វិច៥.១បង្ហាញពីលក្ខណៈប្រជាសាស្ត្រនៃភូមិចំនួន ១១ នៅក្បែរទីតាំងគម្រោងដែលបានធ្វើការអង្កេត។

ក្រាហ្វិច៥.៣.១៖ ស្ថិតិប្រជាពលរដ្ឋតាមភូមិនីមួយៗដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគ



ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

Draft

លើសពីនេះ កំណើន និងការថយចុះនៃចំនួនប្រជាជនក៏ខុសគ្នាគួរឱកត់សម្គាល់ដែរ។ តារាង៥.១ បង្ហាញសង្ខេបពីស្ថានភាពប្រជាសាស្ត្រ និងបម្រែបម្រួលសមាសធាតុប្រជាជននៅក្នុងឃុំនីមួយៗដែលពាក់ព័ន្ធនឹងគម្រោងក្នុងចន្លោះឆ្នាំ២០១៤-២០១៥។ ចំនួនប្រជាជនក្នុងឃុំប៉ង់មានការធ្លាក់ចុះ ៨% ខណៈដែលចំនួនប្រជាជនក្នុងឃុំហាតប៉ក់ធ្លាក់ចុះរហូតដល់ ១២.៥% នៅក្នុងឆ្នាំ២០១៥នេះ ដោយសារអត្រាមរណភាព និងការធ្វើចំណាកស្រុក។ ផ្ទុយពីភូមិទាំងពីរខាងលើ ការសិក្សានេះបានរកឃើញថា ចំនួនគ្រួសារនិងប្រជាជនក្នុងឃុំភ្នំកុក និងឃុំតាឡាតមានការកើនឡើងជាលំដាប់ ដោយសារការរៀបចំគ្រួសារថ្មី(រៀបអាពាហ៍ពិពាហ៍)ជាបន្តបន្ទាប់។ ជាក់ស្តែងចំនួនប្រជាជនក្នុងឃុំភ្នំកុកមានការកើនឡើងចំនួន ៥.២% ចំណែកឯ នៅក្នុងឃុំតាឡាតមានការកើនឡើងចំនួន ២.៨% នៅក្នុងឆ្នាំ២០១៥។ ទិន្នន័យ (តារាង៥.១) បានបង្ហាញផងដែរថា នៅក្នុងឃុំប៉ង់ ភាគរយស្ត្រីជាមេគ្រួសារមានការកើនឡើងគួរឲ្យកត់សម្គាល់ ប្រមាណ១១%-១៤.៩% និង ៩.២%ទៅ១០.៥%នៅក្នុងឃុំភ្នំកុក។ ផ្ទុយទៅវិញ នៅក្នុងឃុំហាតប៉ក់ ភាគរយនៃស្ត្រីដែលជាមេគ្រួសារមានការថយចុះប្រមាណពី ៧% ទៅ៥% នៅក្នុងឆ្នាំ២០១៥។ ចំណែកឯ ឃុំតាឡាតវិញ ភាគរយនៃស្ត្រីដែលជាមេគ្រួសារមិនមានការកើនឡើងឬថយចុះទេ។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មាន ភាពងាយរងគ្រោះខ្ពស់ជាងគេនៅពេលមានបម្រែបម្រួលស្ថានភាពសេដ្ឋកិច្ចនៅក្នុងតំបន់។ ភាពងាយរងគ្រោះរបស់ប្រជាជនទូទៅពីបម្រែបម្រួលស្ថានភាពសេដ្ឋកិច្ចនៅក្នុងតំបន់មានកម្រិតខ្ពស់ ដោយប្រជាជនដែលមានវ័យក្រោម១៧ឆ្នាំ និងវ័យ៦១ឆ្នាំឡើង មានចំនួនរហូតដល់ជិតពាក់កណ្តាលនៃប្រជាជនសរុបនៃឃុំនីមួយៗ ប៉ុន្តែតិចជាងប្រជាជនដែលស្ថិតក្នុងកំលាំងពលកម្ម (វ័យ១៨-៦០ឆ្នាំ) នៃប្រជាជនសរុបរបស់ឃុំនីមួយៗ។

តារាង៥.៣.១៖ លក្ខណៈ និងស្ថានភាពប្រជាសាស្ត្រក្នុងឃុំពាក់ព័ន្ធ

បរិយាយ	ឃុំប៉ង់		ឃុំភ្នំកុក		ឃុំហាតប៉ក់		ឃុំតាឡាត	
	2014	2015	2014	2015	2014	2015	2014	2015
ចំនួនប្រជាជនសរុប (នាក់)	**2,820**	**2,611**	**1,831**	**1,930**	**1,254**	**1,115**	**962**	**990**
%កំណើនប្រជាជនប្រចាំឆ្នាំ		-8.0		5.2		-12.5		2.8
សរុបស្រី	**1,481**	**1,356**	**896**	**976**	**602**	**577**	**497**	**494**
%ស្រី	53	52	49	51	48	52	52	50
ចំនួនគ្រួសារ	**608**	**623**	**424**	**442**	**229**	**258**	**226**	**238**
%កំណើនចំនួនគ្រួសារប្រចាំឆ្នាំ		2.4		4.0		11.2		5.0
%ស្ត្រីជាមេគ្រួសារ	**11**	**14.9**	**9.2**	**10.5**	**7**	**5**	**10**	**10**
ទំហំគ្រួសារជាមធ្យម(នាក់/គ្រួសារ)	4.6	4.7	5.1	5.2	5.3	5.5	4.5	4.5
ចំនួនមនុស្សអាយុ0-១៧ឆ្នាំ	1,245	1,066	889	965	883	752	460	508
%អ្នកមានអាយុ0-១៧ឆ្នាំ	44.1	40.8	48.6	50	70.4	67.4	47.8	51.3
ចំនួនមនុស្សអាយុ១៨-៦0ឆ្នាំ	1,449	1,413	832	863	794	781	451	421
%អ្នកមានអាយុ១៨-៦0ឆ្នាំ	51.4	54.1	45.4	44.7	63.3	70	46.9	42.5
ចំនួនមនុស្សអាយុ៦១ឆ្នាំឡើង	126	132	110	102	63	77	51	61
%អ្នកមានអាយុ៦១ឆ្នាំឡើង	4.5	5.0	6	5.3	5	6.9	5.3	6.1

ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

៥.៤.១.២. ការតាំងទីលំនៅ និងប្រភេទលំនៅដ្ឋាន

លំនៅស្ថានរបស់ប្រជាជននៅក្នុងតំបន់សិក្សាត្រូវបានសង្កេតថាមានលក្ខណៈប្រមូលផ្តុំ នៅអមសងខាងផ្លូវ។[1] យើងក៏សង្កេតឃើញដែរថា ប្រជាជនក្នុងតំបន់នេះចាប់ផ្តើមសាងសង់លំនៅដ្ឋានខុសពីរចនាបថដើម (សាងសង់ពីឈើសុទ្ធ)។ ការផ្លាស់ប្តូរនេះបង្ហាញពីការទទួលយកវប្បធម៌ពីខាងក្រៅ ដែលអាចជាឥទ្ធិពលនៃលំហូរចូលនៃអ្នកចំណូលថ្មីក្នុងភូមិ។[2]

ប្រភេទផ្ទះ និងដំបូលផ្ទះ អាចបង្ហាញ ពីកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់ផងដែរ។ ក្រាហ្វិច៥.២ បង្ហាញ ពីប្រភេទលំនៅស្ថានរបស់ប្រជាជន នៅឃុំប៉ង់ ឃុំភ្នំកុក ឃុំហាតប៉ក់និងឃុំតាឡាតដោយកំណត់តាមរយៈប្រភេទដំបូលផ្ទះ។ លទ្ធផលបានបង្ហាញដូចតទៅ ភូមិដែលពាក់ព័ន្ធទាំង៤មានផ្ទះប្រក់ដំបូលក្បឿងតិចជាងប្រភេទផ្ទះផ្សេងៗទៀត។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៥ ភូមិប៉ង់មានតែ៤%នៃចំនួនផ្ទះសរុបទាំងអស់នៅក្នុងឃុំ ឃុំភ្នំកុកមាន១% ឃុំហាតប៉ក់មាន១២% ហើយឃុំតាឡាតមានតែ៥%ប៉ុណ្ណោះ។ ទោះបីជាចំនួននៃផ្ទះប្រភេទនេះមានតិចតួចក្តី ក៏ចំនួនរបស់ផ្ទះប្រភេទនេះមានការកើនឡើងបន្តិចផងដែរ បើយើងធ្វើការធៀបទៅនឹងឆ្នាំ២០១៤ ដែលក្នុងនោះឃុំប៉ង់មានការកើនឡើងចំនួន៣% ឃុំភ្នំកុកមានការកើនឡើង១% ឃុំហាតប៉ក់កើនឡើងចំនួន២% និងឃុំតាឡាតកើនឡើង១%។

ចំណែកឯប្រភេទផ្ទះប្រក់សង្កសី/ហ្វីប្រូស៊ីម៉ង់ ត្រូវបានរកឃើញថាមានចំនួនច្រើននៅក្នុងឃុំប៉ង់និងឃុំភ្នំកុក គួយ៉ាងឃុំប៉ង់មានចំនួន៥៧%និងឃុំភ្នំកុក ៨៣%នៅក្នុងឆ្នាំ២០១៥។ យ៉ាងណាមិញក្នុងឃុំហាតប៉ក់ប្រភេទផ្ទះប្រក់សង្កសី/ហ្វីប្រូស៊ីម៉ង់នេះមានត្រឹមតែ១៥% និងឃុំតាឡាតមានត្រឹមតែ ២៥% ក្នុងឆ្នាំ២០១៥។ យោងទៅតាមលទ្ធផលដែលបានបង្ហាញក្នុងតារាង ៥.៣ ដដែល ប្រភេទផ្ទះនេះក៏មានចំនួនកើនឡើងផងដែរបើធៀបទៅនឹងឆ្នាំ២០១៤។ នៅក្នុងឃុំប៉ង់ផ្ទះប្រភេទនេះកើនឡើងចំនួន៩% ឃុំភ្នំកុកកើនឡើង៥% ឃុំហាតប៉ក់កើនឡើង១០% និងឃុំតាឡាតកើនឡើងចំនួន៥%។

គួរឲ្យកត់សម្គាល់ថា ចំនួនផ្ទះដំបូលប្រក់ស្លឹកស្វាក្នុងឃុំទាំងបួន មានការធ្លាក់ចុះពីឃុំមួយទៅឃុំមួយ។ ក្នុងឃុំប៉ង់ផ្ទះប្រភេទនេះបានធ្លាក់ចុះពី ៤២% ក្នុងឆ្នាំ២០១៤ មកត្រឹម ៣០% ក្នុងឆ្នាំ២០១៥ រីឯផ្ទះដំបូលប្រក់ស្លឹកស្វាក្នុងឃុំភ្នំកុកធ្លាក់ចុះពី ១៧% ក្នុងឆ្នាំ២០១៤ មកត្រឹម ១២% ក្នុងឆ្នាំ ២០១៥។ ចំណែកឯក្នុងឃុំហាតប៉ក់ ផ្ទះប្រភេទនេះបានថយចុះពី៨០%មកត្រឹម៦៨% និងក្នុងឃុំតាឡាតបានធ្លាក់ចុះពី៧៦%មក៧០%។


លទ្ធផលនេះបង្ហាញឲ្យឃើញថា ជីវភាពប្រជាជននៅក្នុងតំបន់មានភាពធូរធារជាងមុន និងមានកំណើនផ្នែកសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទោះបីជាយ៉ាងក៏ដោយ យើងនៅមិនទាន់អាចសន្និដ្ឋានបានទេថាតើកំណើនកម្រិតជីវភាពនេះមាននិរន្តរភាព ឬយ៉ាងណានោះទេ ព្រោះថាមានកត្តាផ្សេងៗទៀតជាច្រើនអាចជះឥទ្ធិពលទៅលើនិរន្តភាពនៃកំណើនជីវភាពរបស់ប្រជាជន។

1 តាមការសង្កេតក្នុងពេលចុះអង្កេតតាមគ្រួសារ ខែមករា-កុម្ភៈឆ្នាំ២០១៦

2 តាមការសង្កេតក្នុងពេលចុះអង្កេតតាមគ្រួសារ ខែមករា-កុម្ភៈឆ្នាំ២០១៦

Draft

ក្រាហ្វិច៥.៣.២៖ ស្ថានភាពលំនៅដ្ឋានប្រជាពលរដ្ឋនៅក្នុងឃុំពាក់ព័ន្ធ




ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

៥.៤.១.៣. ការអប់រំ

ការអប់រំគឺជាគ្រឹះមួយដ៏សំខាន់ក្នុងការកសាងធនធានមនុស្សនិងជាមូលដ្ឋានក្នុងការចូលរួមលុបបំបាត់ភាពក្រីក្រនៅក្នុងតំបន់។ ប្រសិនបើប្រជាជនក្នុងតំបន់មួយទទួលបានការអប់រំខ្ពស់ តំបន់នោះទៀតសោតនឹងមានការរីកចំរើន ហើយប្រជាជនក៏នឹងមានជីវភាពធូរធារផងដែរ។ តាមរយៈការសិក្សាស្ទង់មតិជាមួយប្រជាជនតាមគ្រួសារក្នុងតំបន់ពាក់ព័ន្ធ លទ្ធផលបានបង្ហាញថាកម្រិតអនក្ខរកម្មតាមចន្លោះអាយុនៅតែបន្តមាននៅក្នុងតំបន់នៅឡើយ។ ក្រាហ្វិច ៥.៣ បង្ហាញពីកម្រិតអនក្ខរកម្មរបស់ប្រជាជននៅក្នុងតំបន់ជាភាគរយ។ នៅឃុំប៉ង់ អ្នកមិនចេះអក្សរក្នុងចន្លោះអាយុ១៥ទៅ២៤ឆ្នាំ មានចំនួន ២៤% និងអ្នកមិនចេះអក្សរក្នុងចន្លោះអាយុ ២៥ទៅ៤៥ឆ្នាំ មាន៥៧% នៅឃុំភ្នំកុក អ្នកមិនចេះអក្សរក្នុងចន្លោះអាយុ ១៥ និង២៤ឆ្នាំ មានតែ ៣០% ប៉ុណ្ណោះ ចំណែកឯ អ្នកមិនចេះអក្សរក្នុងចន្លោះអាយុ ២៥ទៅ៤៥ឆ្នាំ មានរហូតដល់ ៤៣% ។ ដោយឡែក យើងសង្កេតឃើញថា នៅក្នុងឃុំហាតប៉ក់ និងឃុំតាឡាត អ្នកមិនចេះអក្សរដែលស្ថិតក្នុងអាយុ ១៥ទៅ២៤ ឆ្នាំ មានចំនួនច្រើនជាងឃុំទាំងពីរខាងលើ។ ជាក់ស្តែង ឃុំប៉ង់ និងឃុំហាតប៉ក់ អ្នកមិនចេះអក្សរក្នុងចន្លោះអាយុ ២៥-៤៥ឆ្នាំ មាន៥៧% និង៦០% តាមលំដាប់លំដោយ ។

ក្រាហ្វិច៥.៣.៣៖ ភាគរយនៃអ្នកមិនចេះអក្សរក្នុងឃុំពាក់ព័ន្ធ



ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

ភាពខ្វះខាតនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធអប់រំ ប្រហែលជាកត្តាចម្បងបំផុតដែលធ្វើឲ្យការអប់រំក្នុងតំបន់ពាក់ព័ន្ធមួយចំនួន (ជាពិសេស ឃុំភ្នំកុក និងឃុំហាតប៉ក់) មានកម្រិតទាប។ ដូចបង្ហាញក្នុងតារាង ៥.២ នៅក្នុងឃុំភ្នំកុក និងឃុំហាតប៉ក់ មានសាលាបឋមសិក្សាតែ ២ ប៉ុណ្ណោះ ចំណែកឯ ឃុំប៉ង់ មានសាលាបឋមសិក្សា ចំនួន ៣ រីឯឃុំតាឡាតមានសាលាបឋមសិក្សាចំនួន ៦។ ជារួម ឃុំទាំង៤ ខាងលើ មានសាលាបឋមសិក្សាសរុបត្រឹមតែ ១៣ ប៉ុណ្ណោះ។ ចំណែកឯអនុវិទ្យាល័យវិញ មិនមានឡើយនៅក្នុងឃុំភ្នំកុក និងឃុំហាតប៉ក់ ចំណែកឯឃុំប៉ង់និង ឃុំតាឡាត មានអនុវិទ្យាល័យតែចំនួន០១ក្នុងឃុំនីមួយៗ។ គួរឲ្យកត់សម្គាល់ គ្មានឃុំណាមួយមានវិទ្យាល័យទេ។ ទន្ទឹមនឹងនេះដែរ គ្រូបង្រៀនបឋមសិក្សា ក៏ហាក់ដូចជាមានចំនួនមិនគ្រប់គ្រាន់ដែរ។ ជាក់ស្តែង ផលធៀបសិស្សនិងគ្រូបង្រៀនបឋមសិក្សា មានអត្រារហូតដល់ ៥៤.៤ នៅក្នុងឃុំហាតប៉ក់ រីឯផលធៀបសិស្សនិងគ្រូបង្រៀនអនុវិទ្យាល័យ មានអត្រារហូតដល់ ១៨.៩ សម្រាប់ឃុំប៉ង់ ។

តារាង៥.៣.២៖ ស្ថានភាពសិស្សនិងគ្រូបង្រៀន


បរិយាយ	ឃុំប៉ង់			ឃុំភ្នំកុក			ឃុំហាតប៉ក់			ឃុំតាឡាត		
	បឋម	អនុវិទ្យាល័យ	វិទ្យាល័យ	បឋម	អនុវិទ្យាល័យ	វិទ្យាល័យ	បឋម	អនុវិទ្យាល័យ	វិទ្យាល័យ	បឋម	អនុវិទ្យាល័យ	វិទ្យាល័យ
ចំនួនសាលា	3	1	0	2	0	0	2	0	0	6	1	0
ចំនួនបន្ទប់	14	5	0	8	0	0	8	0	0	23	5	0
ចំនួនថ្នាក់	12	3	0	6	0	0	12	0	0	38	3	0
ចំនួនសិស្ស	586	208	0	135	0	0	544	0	0	691	45	0
ចំនួនគ្រូ	14	11	0	9	0	0	10	0	0	18	6	0
ផលធៀបសិស្សនិងគ្រូ	41.9	18.9	0	15	0	0	54.4	0	0	38.3	7.5	0

ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

របាយនៃសាលារៀនដែលមានចំនួនតិចតួច អាចជះឥទ្ធិពលដល់សិស្សតាមរយៈការបង្កភាពលំបាកក្នុងការធ្វើដំណើរទៅសាលារៀន។ ទោះបីជាយ៉ាងណាក៏ដោយ យើងសង្កេតឃើញថា ទីតាំងនៃសាលារៀនបឋមសិក្សានៅ

ក្នុងឃុំនីមួយៗ ហាក់ដូចជាមិនសូវឆ្ងាយពីចំណុចកណ្តាលភូមិនៃឃុំនីមួយៗឡើយ។ ប៉ុន្តែសម្រាប់ថ្នាក់អនុវិទ្យាល័យសិស្សអនុវិទ្យាល័យត្រូវធ្វើដំណើរជាមធ្យមក្នុងមួយថ្ងៃច្រើនជាងសិស្សថ្នាក់បឋមសិក្សា។ តួយ៉ាងនៅក្នុងឃុំភ្នំកុកដើម្បីទៅសាលារៀនបាន សិស្សត្រូវធ្វើដំណើរចម្ងាយជាមធ្យមប្រមាណ ៦៧ គ.ម (ចម្ងាយពីចំណុចកណ្តាលភូមិទៅវិទ្យាល័យ) រីឯសិស្សអនុវិទ្យាល័យក្នុងឃុំហាតប៉ក់ ត្រូវធ្វើដំណើរចម្ងាយជាមធ្យម ៥៤ គ.ម និងក្នុងឃុំតាឡាតប្រមាណជា ៣៩ គ.ម។ ចំណែកឯ សិស្សវិទ្យាល័យក្នុងឃុំប៉ង់ ត្រូវធ្វើដំណើរចំងាយជាមធ្យមតែ ៥០ គ.ម ប៉ុណ្ណោះ (ក្រាហ្វិច៥.៤)។ ដូច្នេះ ចម្ងាយផ្លូវធ្វើដំណើរ ហាក់ដូចជាមិនសូវជាឧបសគ្គ សម្រាប់សិស្សបឋមសិក្សាតែជាឧបសគ្គសម្រាប់សិស្សានុសិស្ស ថ្នាក់អនុវិទ្យាល័យក្នុងការធ្វើដំណើរទៅរៀន។


ក្រាហ្វិច៥.៣.៤៖ ចម្ងាយមធ្យមពីកណ្តាលភូមិទៅសាលា



ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

កត្តាផ្សេងទៀត (ឧ. កត្តាជីវភាព កម្រិតអប់រំរបស់មេគ្រួសារ) អាចជាកត្តាធ្វើឲ្យសិស្សមួយចំនួនធំបោះបង់ការសិក្សាដើម្បីជួយការងារក្នុងគ្រួសារ បន្ទាប់ពីពួកគេបានបញ្ចប់បឋមសិក្សា។ ម្យ៉ាងទៀត កម្រិតអប់រំរបស់មេគ្រួសារ ទំនងជាកត្តាមួយផ្សេងទៀត ដែលជម្រុញឲ្យសិស្សមួយចំនួនបោះបង់ការសិក្សា ដោយសារមេគ្រួសារមិនបានយល់ច្បាស់ពីសារសំខាន់នៃការអប់រំ និងទំនងជាមិនបានជំរុញលើកទឹកចិត្តកូនចៅរបស់ខ្លួនរៀនសូត្រឲ្យបានខ្ពង់ខ្ពស់។ ជាក់ស្តែង ក្រាហ្វិច៥.៥ បង្ហាញថា មេគ្រួសារ ៥% នៃ៣១៨គ្រួសារក្នុងឃុំពាក់ព័ន្ធ មិនបានចូលរៀនសោះ និងមេគ្រួសាររហូតដល់ ៨០% បានបញ្ចប់ត្រឹមបឋមសិក្សា។ មេគ្រួសារចំនួន៧% បានបញ្ចប់អនុវិទ្យាល័យ ហើយ មេគ្រួសារតែ ៨% ប៉ុណ្ណោះ បានបញ្ចប់វិទ្យាល័យ (ក្រាហ្វិច៥.៥)។

ក្រាហ្វិច៥.៣.៥៖ កម្រិតអប់រំខ្ពស់បំផុតរបស់មេគ្រួសារ



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភា និងធ្នូ ឆ្នាំ២០១៦)

៥.៤.១.៤. ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការដឹកជញ្ជូន

នៅក្នុងតំបន់សិក្សាដែលគ្របដណ្តប់លើឃុំចំនួន០៤ គឺឃុំប៉ង់ ឃុំភ្នំកុក ឃុំហាតប៉ក់និងតាឡាត យើងសង្កេតឃើញថា ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាពិសេសផ្លូវគមនាគមន៍នៅមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយទេ គឺផ្លូវធ្វើដំណើរ មានការលំបាក។ ជាក់ស្តែង ផ្លូវឆ្លងកាត់ចូលទៅក្នុងភូមិរំពាត់ និងតាឡាត នៃឃុំតាឡាតត្រូវឆ្លងទូក និងភូមិហាតប៉ក់និងភូមិឡាំប៉ាក់ នៃឃុំហាតប៉ក់ និងភូមិប៉ុងនិងភូមិហ្វាំងនៃឃុំប៉ង់ផ្លូវមានការលំបាកខ្លាំង គឺស្ទើរតែគ្មានផ្លូវសម្រាប់ឡានឆ្លងកាត់។ ចំណែកឯឃុំភ្នំកុក ក៏មិនទាន់មានផ្លូវស្អាតដែរ គ្រាន់តែជាប្រភេទផ្លូវក្រាលគ្រួសក្រហមដែលធ្វើឲ្យមានការហុយធូលីខ្លាំងនៅរដូវប្រាំង។ ចំណែកឯស្ពានឆ្លងកាត់តាមអូរនីមួយៗក៏ជាស្ពានចាស់មិនសូវមានសុវត្ថិភាពក្នុងការឆ្លងកាត់សម្រាប់យានយន្តធំៗដែរ។ រីឯគម្រោងអាចនឹងធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ដោយហេតុថាក្រុមហ៊ុនសាងសង់ផ្លូវ ដើម្បីបង្កភាពងាយស្រួលដល់ការធ្វើដំណើរចូលដល់ទីតាំងគម្រោង ហើយក្រុមហ៊ុននឹងផ្តល់លទ្ធភាពឲ្យប្រជាជនក្នុងតំបន់ប្រើប្រាស់ផ្លូវជាធម្មតា។

ដោយឡែកចំពោះមធ្យោបាយដឹកជញ្ជូននៅក្នុងតំបន់ គឺនៅមិនទាន់មានលក្ខណៈល្អប្រសើរ ដោយមិនមានរថយន្តសម្រាប់ដឹកទំនិញធន់តូច និងធន់ធំគ្រប់គ្រាន់ នៅក្នុងឃុំ និងនៅមិនទាន់មានមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់នៅឡើយទេ (តារាង៥.៤)។

តារាង៥.៣.៣៖ ផ្ទៃដី និងផ្លូវនៅក្នុងតំបន់សិក្សា (ទិន្នន័យឆ្នាំ២០១៥)

បរិយាយ		ឃុំប៉ង់	ឃុំភ្នំកុក	ឃុំហាតប៉ក់	ឃុំតាឡាត
សរុបផ្ទៃដីឃុំសង្កាត់		70,487	7,085	7,224	7,660
សរុបប្រវែងផ្លូវ		11,247	11,200	4000	14,970
ក្នុងនោះ	ប្រវែងផ្លូវតាមបណ្តាឃុំ	11,200	11,200	4000	14,970
	ប្រវែងផ្លូវខេត្តស្រុកឆ្លងកាត់តាមបណ្តាឃុំ	47	0	0	0
	ប្រវែងផ្លូវជាតិឆ្លងកាត់តាមបណ្តាឃុំ	0	0	0	0
ផលធៀបប្រវែងផ្លូវនិងផ្ទៃដីឃុំ		1.4	7.1	0	0

ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

តារាង៥.៣.៤៖ មធ្យោបាយដឹកជញ្ជូន (ទិន្នន័យក្នុងឆ្នាំ២០១៥)

បរិយាយ		ឃុំប៉ង់	ឃុំភ្នំកុក	ឃុំហាតប៉ក់	ឃុំតាឡាត
ផលធៀបមធ្យោបាយដឹកជញ្ជូនផ្លូវគោកក្នុង 1000គ្រួសារ		100.3	1.4	16.3	6.7
សរុបមធ្យោបាយដឹកជញ្ជូនជើងគោក		106	11	29	18
ក្នុងនោះមាន	ត្រីចក្រយានយន្ត	1	0	0	0
	រថយន្តដឹកទំនិញធុនតូច	3	0	2	4
	រថយន្តដឹកទំនិញធុនធំ	2	1	4	1
	រថយន្តដឹកអ្នកដំណើរធុនតូច	3	0	0	0
	រថយន្តដឹកអ្នកដំណើរធុនធំ	0	0	0	0
	រថយន្តប្រើប្រាស់ក្នុងគ្រួសារ	45	10	23	13
	គ្រឿងយន្ត គ្រឿងចក្រផ្សេងៗ	52	0	0	0
កង់ដែលអាចប្រើបាន		143	126	98	154
ម៉ូតូ		409	652	350	470
ផលធៀបចំនួនម៉ូតូនិងចំនួនគ្រួសារ		0.7	0.9	0.7	0.6

ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

៥.៤.១.៥. ការប្រើប្រាស់ដី

ការប្រើប្រាស់ដីក្នុងបរិបទនៃស្ថានភាពឃុំ ផ្តោតសំខាន់លើផ្ទៃដីកសិកម្មដំណាំស្រូវ។ តារាង ៥.៥ បង្ហាញអំពីស្ថិតិផ្ទៃដីកសិកម្មដំណាំស្រូវ និងទិន្នផលស្រូវ នៅក្នុងឃុំពាក់ព័ន្ធទាំង០៤។ ក្នុងឆ្នាំ២០១៥ ផ្ទៃដីបានធ្វើស្រែសរុបក្នុងឃុំប៉ង់មានប្រមាណ ៥៥៤ហិកតា ឃុំភ្នំកុកមានប្រមាណ ១,០៤១ហិកតា ក្នុងឃុំហាតប៉ក់មានប្រមាណ ៥១២ហិកតា និងឃុំតាឡាតមានប្រមាណ៥២៣ហិកតា។ ស្រូវវស្សាជាមុខព្រួញសំខាន់បំផុតក្នុងការធ្វើកសិកម្មដំណាំស្រូវសម្រាប់ប្រជាជនក្នុងឃុំទាំង៤ ហើយការដាំដុះស្រូវចំការ ក៏មានភាពចាំបាច់សម្រាប់ប្រជាជនក្នុងឃុំទាំង៤ផងដែរ។

ការដាំដុះស្រូវក្នុងភូមិទាំង៤នេះបានទទួលទិន្នផលប្រមាណពី១.៥-២.៥តោន/ហិកតាចំពោះស្រូវវស្សា និង ០.៨-១.៥តោន/ហិកតាចំពោះស្រូវចំការ។ ផលស្រូវសរុបក្នុងឃុំប៉ង់ ទទួលបានប្រមាណ ៨៣១តោន (ស្មើនឹង ៣០៦.១ គ.ក្រ/នាក់) ឃុំភ្នំកុក ទទួលបានប្រមាណ ១,៥០១តោន (ស្មើនឹង ៤០៨.៩គ.ក្រ/នាក់) ឃុំហាតប៉ក់ ទទួលបានចំនួន១,០៤៥តោន (ស្មើនឹង៦៧៥.៣គ.ក្រ/នាក់) ឃុំតាឡាតទទួលបានចំនួន៧៨៤.៥តោន (ស្មើនឹង ៤៩៧.៣គ.ក្រ/នាក់)។

តារាង៥.៣.៥៖ ស្ថិតិផ្ទៃដីកសិកម្មដំណាំស្រូវ និងទិន្នផលស្រូវ (ទិន្នន័យឆ្នាំ២០១៥)

បរិយាយ	ឃុំប៉ង់	ឃុំភ្នំកុក	ឃុំហាតប៉ក់	ឃុំតាឡាត
សរុបផ្ទៃដីស្រូវប្រាំង (ហ.ត)	0	0	0	0
%ផ្ទៃដីស្រូវប្រាំងបានដាំដុះជាក់ស្តែង	0.0	0.0	0.0	0.0
ទិន្នផលស្រូវប្រាំងជាមធ្យម (តោន/ហ.ត)	0	0	0	0
បរិមាណផលស្រូវប្រាំង (តោន)	0	0	0	0
សរុបផ្ទៃដីស្រូវវស្សា (ហ.ត)	554	1,041	512	523

បរិយាយ	ឃុំប៉ង់	ឃុំភ្នំកុក	ឃុំហាតប៉ក់	ឃុំតាឡាត
%ផ្ទៃដីស្រូវវស្សាបានដាំដុះជាក់ស្តែង	100.4	96.2	81.6	100
ទិន្នផលស្រូវវស្សាជាមធ្យម (តោន/ហ.ត)	1.5	1.5	2.5	1.5
បរិមាណផលស្រូវវស្សា(តោន)	831	1,501.5	1,045	784.5
ផ្ទៃដីបានដាំដុះស្រូវបង្កើនរដូវ (ហ.ត)	0	0	0	0
ទិន្នផលស្រូវជាមធ្យម (តោន/ហ.ត)	0	0	0	0
បរិមាណផលស្រូវបង្កើនរដូវ (តោន)	0	0	0	0
ផ្ទៃដីបានដាំដុះស្រូវចំការ (ហ.ត)	24	51	11	190
ទិន្នផលស្រូវជាមធ្យម (តោន/ហ.ត)	0.9	1.0	1.5	0.8
បរិមាណផលស្រូវចំការ (តោន)	21.6	51.0	16.5	152
បរិមាណផលស្រូវជាមធ្យមក្នុង១នាក់(គ.ក្រ/នាក់)	306.1	408.9	675.3	497.3

ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

នៅក្នុងឃុំទាំង០៤ ក៏មានគ្រួសារមួយចំនួនមិនទាន់មានដីស្រែ ឬចំការផ្ទាល់ខ្លួននៅឡើយទេ។ ដូចបង្ហាញក្នុងតារាង៥.៦ គ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន នៅក្នុងឃុំប៉ង់មានរហូតដល់ ៦១គ្រួសារ នៅក្នុងឃុំភ្នំកុកមានប្រមាណ ៦០ ចំណែកឯនៅក្នុងឃុំហាតប៉ក់មានប្រមាណ ៤០ និងឃុំតាឡាតមានរហូតដល់៦៨។ ដោយឡែកគ្រួសារមានដីស្រែតិចជាង ១ហិកតា នៅក្នុងឃុំប៉ង់មានចំនួន៤៨គ្រួសារ ចំណែកឯនៅក្នុងឃុំភ្នំកុក មានរហូតដល់៩២គ្រួសារ និងឃុំហាតប៉ក់មាន៤៥គ្រួសារ និងឃុំតាឡាតមាន៦៧គ្រួសារ។ ទន្ទឹមនឹងនេះដែរ គ្រួសារមានដីដាំដំណាំចំការតិចជាង ១ហិកតា នៅក្នុងឃុំប៉ង់មានចំនួនច្រើនរហូតដល់១៦០គ្រួសារ ឃុំតាឡាតមានចំនួន១៣៧គ្រួសារ និងឃុំហាតប៉ក់មានដល់១១៨គ្រួសារ រីឯឃុំភ្នំកុកមានចំនួន៩៤គ្រួសារ។ គ្រួសារគ្មានដីដាំដំណាំចំការផ្ទាល់ខ្លួនមានចំនួនប្រហាក់ប្រហែលគ្នា នៅឃុំប៉ង់ និងឃុំភ្នំកុក មាន៣១៨ និង៣៦៣គ្រួសារ នៅក្នុងឃុំតាឡាត មាន១២១ និងឃុំហាតប៉ក់មាន១២៨គ្រួសារ។

តារាង៥.៣.៦៖ ស្ថានភាពដីស្រែចំការកសិករ (ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥)

បរិយាយ	ឃុំប៉ង់	ឃុំភ្នំកុក	ឃុំហាតប៉ក់	ឃុំតាឡាត
គ្រួសារមានដីស្រែតិចជាង១ហិកតា	48	92	45	67
គ្រួសារមានដីដាំដំណាំចំការតិចជាង១ហិកតា	160	94	118	137
គ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន	61	60	40	68
គ្រួសារគ្មានដីដាំដំណាំចំការផ្ទាល់ខ្លួន	318	363	128	121

៥.៤.១.៦. ការប្រើប្រាស់ថាមពល

ប្រភពថាមពលសម្រាប់បំភ្លឺរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់មានដូចជា បណ្តាញអគ្គិសនី អាគុយ បន្ទះសូឡាឡជីវឧស្ម័ន ជាដើម។ ទិន្នន័យស្ថិតិស្ថានភាពឃុំ (តារាង៥.៧) បង្ហាញឲ្យឃើញថា នៅក្នុងឆ្នាំ២០១៤ ប្រជាជនមួយចំនួនធំនៅក្នុងឃុំប៉ង់ (២៤%) និងឃុំភ្នំកុក (៣០%) និងឃុំហាតប៉ក់ (៣៨.៨%) បានតភ្ជាប់បណ្តាញអគ្គី

សនីប្រើប្រាស់សម្រាប់បំភ្លឺ។ ដោយឡែក ប្រជាជននៅក្នុងឃុំតាឡាតចំនួន១.៨%ប៉ុណ្ណោះដែលបានប្រើប្រាស់ភ្លើងអគ្គីសនីសម្រាប់ជាប្រភពថាមពលក្នុងការបំភ្លឺ ។ ប្រភពបំភ្លឺសំខាន់ទី២របស់ប្រជាជនគឺអាគុយ ដែលភាគរយនៃការប្រើប្រាស់មានប្រមាណ ៤៣% នៅក្នុងឃុំប៉ង់ ៥៩.៣% នៅក្នុងឃុំភ្នំកុក និង៥២% នៅក្នុងឃុំហាតប៉ក់។ ផ្ទុយទៅវិញ ប្រជាជននៅក្នុងឃុំតាឡាតរហូតដល់៧២.៨%ប្រើប្រាស់អាគុយជាប្រភពបំភ្លឺដ៏សំខាន់។ ចំណែកឯប្រភពបំភ្លឺដោយបន្ទះសូឡាវិញ ប្រជាជនមួយចំនួនតូចនៅក្នុងឃុំប៉ង់ ឃុំហាតប៉ក់ និងឃុំតាឡាតបានចាប់ផ្តើមប្រើប្រាស់វាសម្រាប់ផ្គត់ផ្គង់ថាមពលក្នុងការបំភ្លឺដែរ។ ជាក់ស្តែងក្នុងភូមិប៉ង់មាន០.៨% ឃុំហាតប៉ក់មាន៣.៧% និងឃុំតាឡាតមាន១.៣%។ សម្រាប់ឡជីវឧស្ម័ន យើងឃើញថាប្រជាជនក្នុងតំបន់មិនទាន់មានការអនុវត្តនៅឡើយទេ។ លើសពីនេះ ប្រជាជនប្រមាណ ២៩.៨%នៅក្នុងឃុំប៉ង់ ៣៨%នៅក្នុងឃុំភ្នំកុក ២៣.៦%នៅឃុំហាតប៉ក់ និងត្រឹមតែ ៥.៣%នៅឃុំតាឡាតមានទូរទស្សន៍ប្រើប្រាស់។ ជារួមតាមរយៈលទ្ធផលដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម ប្រជាជននៅក្នុងឃុំនីមួយៗមានលទ្ធភាពប្រើប្រាស់អាគុយសម្រាប់ជាប្រភពថាមពលក្នុងការផ្គត់ផ្គង់អគ្គិសនីក្នុងការប្រើប្រាស់ប្រចាំថ្ងៃច្រើនជាងគេ។

តារាង៥.៣.៧៖ ប្រភពថាមពល ទិន្នន័យឆ្នាំ២០១៥

បរិយាយ	ឃុំប៉ង់		ឃុំភ្នំកុក		ឃុំហាតប៉ក់		ឃុំតាឡាត	
	ភាគរយ	ចំនួនផ្ទះ	ភាគរយ	ចំនួនផ្ទះ	ភាគរយ	ចំនួនផ្ទះ	ភាគរយ	ចំនួនផ្ទះ
ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី	24	126	30	212	38.8	135	1.8	13
ផ្ទះបំភ្លឺដោយអាគុយ	43	226	59.3	419	52	181	72.8	520
ផ្ទះបំភ្លឺដោយបន្ទះសូឡា	0.8	4	0.0	0	3.7	13	1.3	9
ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន	0	0	0.0	0	0	0	0.0	0
ផ្ទះមានទូរទស្សន៍ប្រើប្រាស់	29.8	157	38	269	23.6	82	5.3	38

ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

យោងតាមទិន្នន័យក្រសួងផែនការ និងការចុះអង្កេតផ្ទាល់នៅមូលដ្ឋានរបស់ក្រុមការងារសិក្សាវាយតម្លៃអុស និងធ្យូង ជាប្រភពថាមពលដ៏សំខាន់សម្រាប់ការចម្អិនអាហាររបស់ប្រជាពលរដ្ឋទូទៅក្នុងតំបន់សិក្សា លើកលែងតែគ្រួសារខ្លះ ដែលមានលទ្ធភាពប្រើឧស្ម័នហ្គាសសម្រាប់ចម្អិនអាហារ។ ផ្អែកតាមស្ថិតិសេដ្ឋកិច្ច-សង្គម គ្រួសារនៅតាមតំបន់ជនបទប្រមាណ ៩១% ប្រើប្រាស់អុសជាប្រភពឥន្ធនៈសម្រាប់ដុតចម្អិនអាហារ (ក្រសួងផែនការ, ២០០៩) ហើយភាគច្រើននៃអ្នកធ្វើការនៅក្នុងផ្ទះបាយគឺជាស្ត្រី (រដ្ឋបាលព្រៃឈើ, ២០០៩)។ បច្ចុប្បន្ន អត្រាប្រជាជនដែលប្រើប្រាស់អុសជាប្រភពឥន្ធនៈសម្រាប់ដុតចម្អិនអាហារមិនមានការប្រែប្រួលគួរឲ្យកត់សម្គាល់នោះទេ បើផ្អែកតាមការសង្កេតជាក់ស្តែងនៅតំបន់សិក្សា។ អុសអាចរកបានពីទីវាល និងតាមព្រៃល្បោះក្បែរលំនៅដ្ឋាន ឬស្រែ-ចំការ។ ដូច្នេះ ប្រសិនបើព្រៃកាន់តែរេចរឹល ប្រជាពលរដ្ឋក្នុងតំបន់អាចនឹងជួបប្រទះនូវបញ្ហាខ្វះប្រភពថាមពលប្រើប្រាស់ប្រចាំថ្ងៃ ឬជាប្រពៃណីក្នុងការចម្អិនអាហាររបស់ពួកគាត់ ហើយស្ត្រីគឺជាអ្នកដែលនឹងទទួលរងគ្រោះខ្លាំងជាងគេ។

៥.៤.១.៧. សន្តិសុខ

តារាង៥.៨ បង្ហាញអំពីស្ថិតិករណីអសន្តិសុខដែលកើតមាននៅក្នុងឃុំពាក់ព័ន្ធទាំង០៤ក្នុងឆ្នាំ២០១៥។ ដោយសារការគ្រប់គ្រងបានល្អរបស់រាជរដ្ឋាភិបាល ជាពិសេសអាជ្ញាធរមូលដ្ឋាន យើងសង្កេតឃើញថា នៅក្នុងតំបន់សិក្សាកម្រមានបញ្ហាអសន្តិសុខខ្លះៗដូចជា ចោរលួចគោ ក្របី ទំនាស់រឿងព្រំប្រទល់ដីស្រែ អំពើហឹង្សាក្នុងគ្រួសារ

និងក្មេងទំនើង ជាដើម។ បញ្ហាក្មេងទំនើងកើតឡើងតែពេលដែលមានពីធីបុណ្យ ការកំសាន្តផ្សេងៗក្នុងភូមិឃុំតែប៉ុណ្ណោះ ហើយតាមធម្មតាគឺមិនមានបញ្ហាអ្វីគួរឱ្យកត់សម្គាល់ទេ។

តារាង៥.៣.៨៖ ស្ថិតិករណីអសន្តិសុខដែលកើតមាននៅក្នុងឃុំពាក់ព័ន្ធ

បរិយាយ	ឃុំប៉ង់	ឃុំក្នុំកុក	ឃុំហាតប៉ក់	ឃុំតាឡាត
ចំនួនករណីឃាតកម្ម ប្លន់ ចាប់ជំរិត	0	0	0	0
ផលធៀបករណីឃាតកម្ម ប្លន់ ចាប់ជំរិតក្នុងប្រជាជន10 ម៉ឺននាក់	0.0	0.0	0.0	0.0
ចំនួនករណីលួច	3	13	0	8
ផលធៀបករណីលួចក្នុងប្រជាជន10ម៉ឺននាក់	106.4	342.4	0.0	217.2
ចំនួនករណីទំនាស់កម្រិតព្រហ្មទ័ណ្ឌ	0	2	1	0
ផលធៀបករណីទំនាស់កម្រិតព្រហ្មទ័ណ្ឌក្នុងប្រជាជន 10ម៉ឺននាក់	0.0	52.7	63.6	0.0
ចំនួនករណីទំនាស់កម្រិតរដ្ឋប្បវេណី	0	8	3	9
ផលធៀបករណីទំនាស់កំរិតរដ្ឋប្បវេណីក្នុងប្រជាជន10 ម៉ឺននាក់	0.0	210.7	190.8	244.4

ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥


៥.៤.២. ស្ថានភាពសេដ្ឋកិច្ច និងសុខុមាលភាពសាធារណៈ

ដើម្បីឲ្យកាន់តែស៊ីជម្រៅនៅក្នុងផ្នែកស្ថានភាពសេដ្ឋកិច្ច ក្រុមការងារបានធ្វើការសិក្សាបន្ថែមទៅលើប្រភេទមុខរបររបស់ប្រជាជននៅក្នុងតំបន់ពាក់ព័ន្ធ ប្រាក់ចំណូលចំណាយប្រចាំឆ្នាំ និងការប្រែប្រួលកម្រិតជីវភាពរបស់ប្រជាជនក្នុងតំបន់ រួមទាំងអនុផលព្រៃឈើដែលមាននៅក្នុងតំបន់ដែលប្រជាជនធ្វើការអាស្រ័យជាមួយ។

៥.៤.២.១. មុខរបរ

ប្រជាពលរដ្ឋនៅក្នុងតំបន់សិក្សាធ្វើការប្រកបរបរចិញ្ចឹមជីវិតដោយពឹងផ្អែកលើរបរក្នុងវិស័យកសិកម្ម (ដូចជា ការដាំស្រូវស្សា ការចិញ្ចឹមសត្វ ការនេសាទជាដើម) សេវាកម្ម (លក់ដូរ ជាងជួសជុល) និងការងារបានប្រាក់កម្រៃប្រចាំថ្ងៃ ឬខែ (ស៊ីឈ្នួល/កម្មករ កម្មកររោងចក្រ បម្រើការរាជការ) ជាដើម។ យ៉ាងណាមិញក្រាហ្វិច៥.៧បានបង្ហាញនូវមុខរបរចំបង៣ ដែលក្នុងនោះមុខរបរចំបង២ស្ថិតក្នុងវិស័យកសិកម្ម៖ ការធ្វើស្រែស្រូវរហូតដល់ទៅជិត៦០% និងស្រូវនិងចំការប្រមាណ២០%។ ចំណែកឯមុខរបរចំបងទី៣ស្ថិតនៅក្នុងវិស័យសេវាកម្មគឺការលក់ដូរមានភាគរយប្រមាណ១០%។ មុខរបរចំបងទាំង៣នេះត្រូវបានប្រជាជនទទួលស្គាល់ថាជាមុខរបរដែលផ្តល់ប្រាក់ចំណូលផងដែរ ហើយបន្ថែមពីលើមុខរបរចំបងទាំងបីនេះ មានមុខរបរ៨ផ្សេងទៀតដែលមិនមែនជាមុខរបរចំបងរបស់ប្រជាជនតែមុខរបរនោះត្រូវបានពួកគាត់ពឹងផ្អែកនឹងចាត់ទុកថាជាមុខរបរដែលផ្តល់ប្រាក់ចំណូលដល់ពួកគាត់ផងដែរ។ មុខរបរទាំងនោះមានដូចជា ការធ្វើចំការដំឡូងមី ការធ្វើចំការស្វាយចន្ទី ការចិញ្ចឹមគោក្របី និងការចិញ្ចឹមមាន់ ទានិងជ្រូក។ ផ្អែកតាមលទ្ធផលដែលបានបង្ហាញខាងលើ ការងារនៅក្នុងវិស័យកសិកម្មគឺជាប្រភេទការងារចំបងនិងជាការងារដែលចូលរួមផ្តល់ប្រាក់កម្រៃដល់ពួកគាត់ច្រើនជាងការងារនៅក្នុងវិស័យផ្សេងៗទៀត។ ។


ក្រាហ្វិច៥.៣.៦៖ មុខរបរចម្បង-បន្ទាប់បន្សំ និងមុខរបរផ្តល់ចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់សិក្សា



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភា និងធ្នូ ឆ្នាំ២០១៦) [សូមពិនិត្យផ្នែកខាងក្រោមតារាង កសិកម្ម សេវាកម្ម និងការងារបានប្រាក់កម្រៃ]

ដោយធ្វើការបូកសរុបជារួម លទ្ធផលនៃការអង្កេតតាមគ្រួសារបានបង្ហាញថា នៅក្នុងតំបន់សិក្សា មានគ្រួសារច្រើនគួរឲ្យកត់សម្គាល់បានជ្រើសរើសមុខរបរក្នុងវិស័យកសិកម្មជាមុខរបរចំបង ដែលមានអត្រារហូតដល់ ៨៥% ចំណែកឯ គ្រួសារប្រមាណជា ១០% បានជ្រើសរើសយកមុខរបរក្នុងវិស័យសេវាកម្មជាមុខរបរចម្បង។ នៅក្នុងតំបន់សិក្សា មានគ្រួសារប្រមាណត្រឹមតែ ៥% ប៉ុណ្ណោះ ដែលបានជ្រើសរើសយកមុខរបរទទួលបានកម្រៃប្រចាំថ្ងៃ ឬខែ ជាមុខរបរចម្បង។

ក្រាហ្វិច៥.៣.៧៖ មុខរបរចម្បងរបស់គ្រួសារក្នុងអង្កេត




ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភានិងធ្នូ ឆ្នាំ២០១៦)

៥.៤.២.២. ប្រាក់ចំណូលប្រចាំឆ្នាំ

ការសម្ភាសន៍តាមគ្រួសារផ្ទាល់ បង្ហាញថា គ្រួសារក្នុងតំបន់សិក្សា មានប្រភពចំណូលលើសពីមួយ។ ជាមធ្យមក្នុងមួយគ្រួសារមានសមាជិកចូលរួមរកចំណូលចំនួន ២-៣នាក់។ ចំពោះមុខរបរក្នុងវិស័យកសិកម្ម ប្រជាជនអាចរកប្រាក់ចំណូលបានប្រមាណជាមធ្យម ៦៨២ដុល្លារអាមេរិក/ឆ្នាំ/គ្រួសារ (ឬ ៥៦,៨ដុល្លារ/ខែ/នាក់)។ មុខរបរដែលប្រជាជនរកចំណូលបានច្រើនជាងគេ គឺរកផលឈើ ជាទូទៅដូចដែលយើងបានដឹងចំណូលពីការលក់ឈើគឺទទួលបានកម្រៃច្រើនបើប្រៀបធៀបនឹងមុខរបរផ្សេងៗហើយមិនចាំបាច់ចំណាយពេលយូរទៀតផង។ ទោះជាយ៉ាងណា មុខរបររកផលឈើមិនមែនជាមុខរបរស្ថិតស្ថេរនិងទៀងទាត់សម្រាប់គាត់ទេ មុខរបរធ្វើស្រែ ធ្វើចំការ នេសាទ និងចិញ្ចឹមសត្វទើបជាមុខរបរស្ថិតស្ថេរ និងអាចផ្តល់ប្រាក់ចំណូលសមរម្យសម្រាប់ការចិញ្ចឹមជីវិតរបស់ប្រជាជនក្នុងតំបន់។ គួរឱ្យកត់សម្គាល់ មុខរបរដែលទទួលបានប្រាក់ចំណូលប្រចាំឆ្នាំទាបជាងគេបំផុតនោះ គឺ មុខរបរបរបាញ់សត្វព្រៃដោយទទួលបានប្រាក់ចំណូលជាមធ្យមតែ ១៥២ ដុល្លារអាមេរិក/ឆ្នាំ/គ្រួសារប៉ុណ្ណោះ។

ជាទូទៅ យើងសង្កេតឃើញថាប្រជាជនក្នុងមួយគ្រួសារមានមុខរបរច្រើន អាចចាប់ពីពីរឡើងទៅ ដូច្នេះចំពោះចំណូលក្នុងផ្នែកការងារទទួលបានកម្រៃ មុខរបរផ្តល់ប្រាក់ចំណូលច្រើនជាងគេបំផុត គឺមុខរបរលក់ដូរគ្រឿងទេស (២៩២៤ ដុល្លារ/ឆ្នាំ/គ្រួសារ) (ឬ ២៤៣,៦ដុល្លារ/ខែ/នាក់)។ ចំណែកឯមុខរបរដែលផ្តល់ប្រាក់ចំណូលខ្ពស់បន្ទាប់គួរឲ្យកត់សម្គាល់ដែរនោះ គឺមុខរបរក្នុងវិស័យសេវាកម្ម មានដូចជា ស៊ីឈ្នួលជាដើមដែលជាប្រាក់ចំណូលមួយថែរ (ជាមធ្យម ១២៩៩ ដុល្លារ/ឆ្នាំ/គ្រួសារ ឬ ១០៨,២៥ដុល្លារ/ខែ/នាក់)។

ក្រាហ្វិច៥.៣.៨៖ ប្រាក់ចំណូលប្រចាំឆ្នាំតាមប្រភេទមុខរបរ



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភា/ធ្នូ ឆ្នាំ២០១៦)

៥.៤.២.៣. ចំណាយប្រចាំឆ្នាំ


ក្នុងការស្រាវជ្រាវនេះ យើងមិនបានសួរកចំណាយតាមរយៈការចំណាយមួយសប្តាហ៍ ឬ មួយខែចុងក្រោយទៅតាមប្រភេទនៃចំណាយដូចការសិក្សាជាទូទៅនោះទេ។ ដោយហេតុថាប្រជាជនក្នុងតំបន់សិក្សាមានកម្រិតអប់រំ/យល់ដឹងទាប យើងបានប្រើវិធីសាស្ត្រគ្រាប់ពូជទាំង១០ (ដែលជាឧបករណ៍ស្រាវជ្រាវមួយនៃការវាយតម្លៃជនបទដោយមានការចូលរួម ឬ PRA) ដើម្បីបញ្ជៀសភាពស្មុគស្មាញ។ ដើម្បីបានចំណាយដែលងាយស្រួលក្នុងការពិពណ៌នា យើង

បានសួរពីការចំណាយរបស់គ្រួសារនីមួយៗ ដោយឲ្យតំណាងពួកគាត់គិតជាចំនួនភាគរយសរុបប្រចាំឆ្នាំដែលគាត់បានចាយក្នុងប្រាក់ចំណូលសរុបរបស់គាត់១០០%។ ដោយពន្យល់ថាបើក្នុងចំណូលសរុបរបស់ពួកគាត់មាន ១០គ្រាប់ពូជ តើគាត់ចាយទៅវិញអស់ប៉ុន្មានហើយចំនួនដែលសល់បន្ទាប់ពីចំណាយរបស់គាត់យើងគិតថាជាប្រាក់ដែលនៅសល់ (ប្រាក់សន្សំ = ចំណូល – ចំណាយ)។ ដើម្បីវិភាគការចំណាយរបស់គ្រួសារនីមួយៗ យើងតាង ០១គ្រាប់ពូជ ស្មើនឹង ១០%, ០២គ្រាប់ពូជ ស្មើនឹង ២០%, រហូតដល់ ១០គ្រាប់ពូជ ស្មើនឹង ១០០%។ វិធីសាស្ត្រស្រាវជ្រាវលម្អិតមានរៀបរាប់ក្នុងជំពូកទី២។

លទ្ធផល (ក្រាហ្វិច៥.១០) បង្ហាញថា ធៀបនឹងចំណូលសរុប (១០០%) គ្រួសារប្រមាណ ៤% ចំណាយទាំងស្រុង, គ្រួសារប្រមាណ ៣៨% ចំណាយ៨០-៩០%, គ្រួសារប្រមាណ ៤២% ចំណាយ៦០-៧០%, ហើយគ្រួសារប្រមាណ ១១% ចំណាយ៥០%នៃចំណូលសរុប។ នៅក្នុងតំបន់សិក្សា មានតែគ្រួសារប្រមាណ ៥% ចំណាយតិចជាង៥០%នៃចំណូលសរុបប្រចាំឆ្នាំ។ គ្រួសារដែលមានប្រាក់សន្សំច្រើនទាំងនេះ គឺជាគ្រួសារដែលអាចរកប្រាក់ចំណូលលើសពី ៣,៩៧៣ដុល្លារ/ឆ្នាំ (ដូចបង្ហាញក្នុងក្រាហ្វិច៥.១០)។

ការប្រៀបធៀបរវាងចំណូល និងចំណាយ បញ្ជាក់ឲ្យឃើញថា លក្ខខណ្ឌសេដ្ឋកិច្ចក្នុងតំបន់សិក្សា នៅអាចទ្រទ្រង់ដល់ជីវភាពប្រចាំថ្ងៃបានក្នុងពេលបច្ចុប្បន្ន។ ទោះជាយ៉ាងនេះក្តី គ្រួសារដែលចំណាយចាប់ពី ៨០% នៃចំណូលសរុបឡើងទៅ អាចប្រឈមនឹងបញ្ហាជីវភាព ប្រសិនបើធនធានធម្មជាតិដែលពួកគាត់អាស្រ័យផល (ដូចជា ព្រៃឈើ និងប្រព័ន្ធអូរធម្មជាតិ) នៅតែបន្តរេចរឹល ហើយពួកគាត់មិនអាចរក ឬពង្រីកមុខរបរបន្ថែមនោះទេ។

ក្រាហ្វិច៥.៣.៩៖ ចំណាយជាមធ្យមប្រចាំឆ្នាំធៀបនឹងចំណូល (គិតជាភាគរយ)




ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភា និងធ្នូ ឆ្នាំ២០១៦)

Draft

<u>បន្ទាត់ក្រីក្រ៖</u> យោងតាមរបាយការណ៍ក្រសួងផែនការ (ឆ្នាំ2013, ទំព័រ៩)[3] ស្តីពីកម្រិតភាពក្រីក្រសម្រាប់តំបន់ទីប្រជុំជន ប្រជាពលរដ្ឋដែលចំណាយក្រោម 3503រៀល/ថ្ងៃ/នាក់ (0.88ដុល្លារអាមេរិក/ថ្ងៃ/នាក់)[4] អាចចាត់ទុកថាស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រ។ លទ្ធផលនៃការវិភាគលើរបាយនៃការចំណាយប្រចាំថ្ងៃដែលទទួលបានពីការអង្កេតតាមគ្រួសារបង្ហាញថា ក្នុងមួយថ្ងៃប្រជាពលរដ្ឋម្នាក់ចំណាយខ្ពស់ជាងគេ ឬច្រើនជាង 5ដុល្លារ មានប្រមាណ ៨% និងប្រជាពលរដ្ឋមួយនាក់ ចំណាយក្រោម0.88ដុល្លារ ឬ 3503រៀលក្នុងថ្ងៃ មានប្រមាណ ៤7% ដូចនេះមានន័យថានៅក្នុងតំបន់សិក្សាអាចមានប្រជាពលរដ្ឋ ៤៧% ដែលស្ថិតនៅក្រោមបន្ទាត់ក្រីក្រ (ក្រាហ្វិច 5.3.5)។

ក្រាហ្វិច ៥.៣.១០ ចំណាយរបស់មនុស្សម្នាក់ក្នុងមួយថ្ងៃ



ប្រភព៖ អង្កេតតាមគ្រួសារ (ខែឧសភា និងធ្នូ ឆ្នាំ២០១៦)

៥.៤.២.៤. កម្រិតសារៈសំខាន់នៃប្រភេទមុខរបរចំពោះជីវភាព និងបម្រែបម្រួលកម្រិតជីវភាព


ក្រាហ្វិច ៥.១១ បង្ហាញពីកម្រិតសារៈសំខាន់នៃប្រភេទមុខរបរចំពោះជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់សិក្សា និងភាពខុសគ្នានៃកម្រិតសារៈសំខាន់ទាំងនេះរវាងមុនពេលមានគម្រោង និងក្នុងពេលបច្ចុប្បន្ន (ពេលមានគម្រោង)។ ជារួម មុខរបរធ្វើស្រែ និងធ្វើចំការ មានសារៈសំខាន់ជាងមុខរបរផ្សេងទៀតសម្រាប់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់សិក្សា ហើយកម្រិតសារៈសំខាន់នៃមុខរបរទាំងពីរនេះមានការថយចុះសរុបពី ៥១% នៅមុនពេលមានគម្រោង ទៅ ៤៨% ក្នុងពេលបច្ចុប្បន្ន។ កម្រិតសារៈសំខាន់នៃមុខរបរចិញ្ចឹមសត្វ និងមុខរបរផ្សេងទៀតមានដូចជាលក់ដូរដោះដើម (ក្រៅពីរកអនុផលព្រៃឈើ ប្រមូលផលឈើ និងនេសាទ) មានការកើនឡើងបន្តិចបន្តួចនៅមុននិងក្រោយមានគម្រោង។ ការកើនឡើងនៃកម្រិតសារៈសំខាន់នៃមុខរបរទាំងនេះ គឺស្របគ្នានឹងការធ្លាក់ចុះនៃកម្រិតសារៈសំខាន់នៃមុខរបរដូចជា ការរកអនុផលព្រៃឈើ ការប្រមូលផលឈើ និងការនេសាទ។ ជារួមកម្រិតសារៈសំខាន់នៃមុខរបរទាំង០៣នេះ ត្រូវបានរកឃើញថា សម្រាប់មុខរបររកអនុផលព្រៃឈើមានការធ្លាក់ចុះសរុបពី ២២% នៅមុនពេលមានគម្រោង មកត្រឹម ១៥% ក្នុងពេលបច្ចុប្បន្ន នៅក្នុងភូមិឡាំប៉ាក់។ រីឯមុខរបររក

[3] file:///C:/Users/Sophal%20Chhun/Downloads/New%20Poverty%20Line-FINAL%20APR%202013.pdf

[4] ១ដុល្លារអាមេរិក = ៤០០០រៀល

ផលឈើ ជារួមមានការធ្លាក់ចុះពី១៨% មុនមានគម្រោង មកត្រឹម ១១% ក្នុងពេលបច្ចុប្បន្ន នៅក្នុងភូមិហាតប៉ក់។ ជាលទ្ធផលនៃការធ្លាក់ចុះរួមនេះ យើងសង្កេតឃើញថា កម្រិតសារៈសំខាន់នៃមុខរបរអនុផលព្រៃឈើក្នុងពេលបច្ចុប្បន្ន ចំពោះប្រជាជននៅក្នុងភូមិហ្វាំង ភូមិកុកឡាវ ភូមិកុកព្រៅ កាឡែសាពូន កាឡែតាវ៉ាង រំពាត់ និងតាឡាត មានការធ្លាក់ចុះខ្លាំងនៅសល់តែប្រមាណ ១-៣% ប៉ុណ្ណោះ ហើយកម្រិតសារៈសំខាន់នៃមុខរបរប្រមូលផលឈើចំពោះប្រជាជននៅក្នុងភូមិទាំងនេះ ក៏នៅសល់តែប្រមាណ ៣-១០% ដែរ។ ទន្ទឹមនឹងនេះដែរ កម្រិតសារៈសំខាន់នៃមុខរបរនេសាទចំពោះប្រជាជនក្នុងភូមិនៃតំបន់សិក្សាមានការធ្លាក់ចុះតិចតួច ដោយឡែក កម្រិតសារៈសំខាន់នៃមុខរបរនេសាទចំពោះជីវភាពប្រជាជនក្នុងភូមិកាឡែសាពូន ភូមិទៀមក្រោម ភូមិប៉ង់ ភូមិកុកឡាវ កុកព្រៅ ភូមិហ្វាំង ភូមិរំពាត់ និងភូមិតាឡាតមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៅសល់ប្រមាណ២-៦%។

ក្រាហ្វិច៥.៣.១១៖ បម្រែបម្រួលកម្រិតសារៈសំខាន់នៃប្រភេទមុខរបរ



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភានិងធ្នូ ឆ្នាំ២០១៦)

បម្រែបម្រួលនៃកម្រិតសារៈសំខាន់នៃប្រភេទមុខរបរនីមួយៗចំពោះជីវភាពប្រជាជន ឆ្លុះបញ្ចាំងពីការឆ្លើយតបរបស់ប្រជាជនទៅនឹងការអភិវឌ្ឍ បម្រែបម្រួលស្ថានភាពសេដ្ឋកិច្ច និងបរិស្ថានក្នុងតំបន់។ ការអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្មក្នុងតំបន់ អាចនឹងបំផ្លិចបំផ្លាញធនធានព្រៃឈើដែលប្រជាជនមូលដ្ឋានអាស្រ័យផល (ឈើ និងអនុផលព្រៃឈើ) និងអាចនឹងរួមចំណែកធ្វើឲ្យប្រែប្រួលប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹកអូរធម្មជាតិដែលជាជម្រកមច្ឆជាតិ។ ទៅអនាគត មុខរបរពាក់ព័ន្ធនឹងធនធានធម្មជាតិទាំងនេះ (រកអនុផលព្រៃឈើ ប្រមូលផលឈើ និងនេសាទ) អាចធ្លាក់ចុះដោយសារប្រភពធនធានកាន់តែរេចរឹល។ ដូច្នេះ ដើម្បីបំពេញតម្រូវការជីវភាពប្រចាំឆ្នាំគ្រួសារនីមួយៗចាំបាច់ត្រូវរកមុខរបរបន្ថែម ឬពង្រីកមុខរបរណាមួយទៅតាមលទ្ធភាពដែលអាចធ្វើបាន។

បម្រែបម្រួលយុទ្ធសាស្ត្រនៃការប្រកបរបរចិញ្ចឹមជីវិតដើម្បីឆ្លើយតបនឹងស្ថានភាពនៃការអភិវឌ្ឍក្នុងតំបន់ បានធ្វើឲ្យគ្រួសារប្រមាណ ៥១% មានកម្រិតជីវភាពកើនឡើង ពាក់កណ្តាលនៃចំនួនសំណាកដែលបានសម្ភាសន៍។ ដោយឡែក គ្រួសារប្រមាណ ២០% មានកម្រិតជីវភាពថយចុះ និងគ្រួសារប្រមាណ ២៣% មានកម្រិតជីវភាពនៅដដែល និង ៦% មិនមានយោបល់ក្នុងពេលសម្ភាសន៍(តារាង៥.៩)។ ប្រជាពលរដ្ឋដែលគិតថា ជីវភាពរបស់គ្រួសារគាត់មានការកើនឡើងភាគច្រើនគឺជាគ្រួសារដែលប្រកបរបរចំបងធ្វើចំការ និងមុខរបរបន្ទាប់បន្សំផ្សេងទៀតដូចជាចិញ្ចឹមសត្វជាដើម។ ប្រជាជនដែលមានជីវភាពកើនឡើងបានអះអាងថា ដោយពួកគាត់មានដីធ្វើចំការ (ឧ.

ដាំដំឡូងមី) ដូច្នេះគ្រួសារពួកគាត់អាចរកចំណូលបានច្រើនជាងមុន។ ទន្ទឹមនឹងនេះ ហេតុផលមួយចំនួនដែលពួកគាត់បានលើកឡើងទាក់ទងទៅនឹងការកើនឡើងនៃជីវភាពនេះមានដូចជាធ្វើស្រែបានផលច្រើនជាងមុន និងលក់ដូរដោចជាងមុន និងមានឈ្មួញចូលមកទិញដំណាំកសិផលរបស់ពួកគាត់ដល់ក្នុងភូមិ។ ចំណែកឯប្រជាជនដែលឆ្លើយថាជីវភាពគ្រួសារគាត់ថយចុះ គឺដោយហេតុផលថា ពួកគាត់មិនអាចចូលព្រៃក្នុងដីក្រុមហ៊ុនដងជ័រទឹកបាន និងរកឈើមិនបានដូចមុន គ្រោះធម្មជាតិនិងធ្វើស្រែបានទិន្នផលទាបជាដើម។ ដូច្នេះពួកគាត់មិនអាចរកអនុផលព្រៃឈើ ផលឈើ ហើយផលនេសាទក៏ធ្លាក់ចុះដែរ។ ចំពោះអ្នកដែលឆ្លើយតបថាជីវភាពគ្រួសារគាត់មិនមានការប្រែប្រួល ភាគច្រើនជាអ្នកដែលមិនទទួលរងផលប៉ះពាល់ដោយសារគម្រោងវិនិយោគ។ ពួកគាត់បានអះអាងថា ពីមុនពេលមានគម្រោង ក៏គ្រួសារគាត់មានដីស្រែចំការប៉ុណ្ណឹង ដូច្នេះការប្រមូលផលក៏មិនមានការប្រែប្រួលដែរ (សម្ភាសន៍ប្រជាជនផ្ទាល់ ខែឧសភា ឆ្នាំ២០១៦)។

តារាង៥.៣.៩៖ បម្រែបម្រួលជីវភាពគ្រួសារមុន និងក្រោយមានគម្រោង

ស្ថានភាពជីវភាពមុន និងក្រោយគម្រោង	គិតជាភាគរយ	មូលហេតុនៃបម្រែបម្រួល	គិតជាភាគរយ
ធូរធារជាងមុន	៥១%	ធ្វើស្រែចំការបានផលច្រើន	៥៤%
		លក់ដូរដោចជាងមុន	១៥%
		មានឈ្មួញចូលទិញដល់ភូមិ	៤%
		មិនសូវឈឺ	៤%
មិនប្រែប្រួល	២៣%	ឈឺ	២២%
		ចិញ្ចឹមសត្វមិនសូវបាន(ស្លាប់ច្រើន)	១៦%
		គ្មានដីស្រែពង្រីកថែម	៣៣%
		មិនមានមុខរបរពង្រីកបន្ថែម	២១%
		ធ្វើស្រែបានផលតិចតួច	៨%
យ៉ាប់ជាងមុន	២០%	បាត់បង់ដើមដំទឹក	២៦%
		អស់ព្រៃឈើ	៣៨%
		គ្រោះធម្មជាតិ	៨%
		រកត្រីមិនសូវបាន	៤%
		ឈឺច្រើន	៩%
		ធ្វើស្រែបានទិន្នផលទាប	១៤%

Draft

មិនមានយោបល់	៦%

ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភានិងធ្នូ ឆ្នាំ២០១៦)

៥.៤.២.៣. ធនធានផលអនុផលព្រៃឈើ

ឆ្លងតាមរយៈការពិភាក្សាជាមួយប្រជាជននៅក្នុងតំបន់ដូចជា អ្នកដឹងច្បាស់ជំរទឹក អ្នករកផលអនុផលព្រៃឈើ ប្រជាជនដែលធ្វើស្រែចំការនៅឆ្ងាយពីភូមិ អ្នកប្រើប្រាស់ និងអ្នកធ្វើការជួញដូរផលអនុផលព្រៃឈើនៅក្នុងនឹងក្បែរទីតាំងតំបន់គម្រោងរួចមកទទួល ជាលទ្ធផលនៅក្នុងនឹងនៅក្បែរទីតាំងតំបន់គម្រោងមានប្រភេទផលអនុផលព្រៃឈើទាំងអស់មានចំនួនប្រមាណ ៣៨ប្រភេទ(តារាង៥.១០) និងមានដំណុះប្រភេទរុក្ខជាតិឱសថទាំងអស់ចំនួនប្រមាណ៤៧ប្រភេទដែលប្រជាជនមូលដ្ឋានយកមកប្រើប្រាស់ក្នុងការព្យាបាលជម្ងឺ(តារាង៥.១១)។ កំឡុងពេលបច្ចុប្បន្នក៏នៅតែមានប្រជាជននៅក្នុង ឃុំភ្នំកុក ឃុំហាក់ប៉ក់ និងឃុំតាឡាត ក៏ដូចជាភូមិហ្វាំង ភូមិប៉ុង ភូមិកាឡែសាពូន ភូមិទៀមក្រោម ភូមិហាត់ប៉ក់ ភូមិតាឡាត និងភូមិរំពាត់ ដែលពួកគាត់តែងតែចេញទៅរកផល-អនុផលទាំងនេះយកមកប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់គាត់ទៅតាមរដូវកាលផងដែរ។

តារាង៥.៣.១០៖ បង្ហាញអំពីប្រភេទផលអនុផលព្រៃឈើដែលមាននៅក្នុង និងក្បែរទីតាំងតំបន់គម្រោង

ល.រ	ឈ្មោះខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	រដូវកាលដែលមាន និងអាចរកបាន
១	ក្តួច	*Dioscorea hispida Denn*	ពេញមួយឆ្នាំ
២	ដំឡូងទៀន	*Dioscorea brevipetiolata Prain & Burkill*	ពេញមួយឆ្នាំ
៣	ដំឡូងជ្រូក	*Dioscorea oryzetorum*	ពេញមួយឆ្នាំ
៤	ដំឡូងទឹក	*Dioscorea pentaphylla L.*	ពេញមួយឆ្នាំ
៥	រំដេង	*Alpinia galangal*	ពេញមួយឆ្នាំ
៦	ចុងផ្តៅ	-	ពេញមួយឆ្នាំ
៧	ត្រួយរាំង	*Barringtonia acutangula*	ចុងខែឧសភា-ពាក់កណ្តាលខែកក្តដា
៨	ផ្តៅចាហួយ	*Curcuma alismatifolia*	ចុងខែឧសភា-ពាក់កណ្តាលខែកក្តដា
៩	ទំពាំង	-	ចុងខែមិថុនា-សីហា
១០	ស្លឹកព្រិច	*Melienthes suavis*	ចុងខែឧសភា-ពាក់កណ្តាលខែកក្តដា
១១	ត្រួយប៉ប្រើស	*Smilax glabra*	ចុងខែឧសភា-ពាក់កណ្តាលខែកក្តដា
១២	ត្រួយល្វៀង	*Cratoxylum formosum subsp.formosum*	ពេញមួយឆ្នាំ
១៣	ផ្សិតប៉ក់	-	ចុងខែឧសភា-ពាក់កណ្តាលខែកក្តដា
១៤	ផ្សិតឈើ	-	ចុងខែឧសភា-ពាក់កណ្តាលខែកក្តដា

ល.រ	ឈ្មោះខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	រដូវកាលដែលមាន និងអាចកេបាន
១៥	ផ្សិតកញ្ជោ	-	ចុងខែឧសភា-ពាក់កណ្តាលខែកក្កដា
១៦	ផ្សិតក្ងោក	-	ចុងខែឧសភា-ពាក់កណ្តាលខែកក្កដា
១៧	ផ្លែគុយ	*Willughbeia edulis*	ខែមេសា- ខែកក្កដា
១៨	ផ្លែសិរមាន់	*Nephelium hypoleucum*	ខែមេសា- ខែកក្កដា
១៩	ផ្លែក្ងៀវ	*Baccaurea ramiflora Lour*	ខែមេសា- ខែកក្កដា
២០	ផ្លែពង្រ	*Schleicheria trijuga Willd.*	ខែមេសា- ខែកក្កដា
២១	ផ្លែម៉ាកព្រេង	-	ខែមេសា- ខែកក្កដា
២២	ផ្លែម៉ាកប្រាំង	*Bouea oppositifolia*	ខែមេសា- ខែកក្កដា
២៣	ផ្លែព្រីង	*Syzygium lineatum Blum*	ខែមេសា- ខែកក្កដា
២៤	ផ្លែព្រូស	*Garcinia ferrea Pierre*	ខែមេសា- ខែកក្កដា
២៥	ផ្លែជន្លួស	-	ខែមេសា- ខែកក្កដា
២៦	ផ្លែកន្ធតព្រៃ	*Phyllandthus emblica L.*	ខែមេសា- ខែកក្កដា
២៧	ឃ្មុំ	-	ពេញមួយឆ្នាំ
២៨	ហ៊ឹង	-	ពេញមួយឆ្នាំ
២៩	ឫស្សី	-	ពេញមួយឆ្នាំ
៣០	គីង្គក់	-	ពេញមួយឆ្នាំ
៣១	ដំរចុង	-	ពេញមួយឆ្នាំ
៣២	ដើមរុន	-	ពេញមួយឆ្នាំ
៣៣	ប្រស្វា	-	ពេញមួយខែវស្សា
៣៤	ចុងស្តៅ	-	ពេញមួយឆ្នាំ
៣៥	វល្លិថ្នឹង	-	ពេញមួយឆ្នាំ
៣៥	ដើមធ្មេញត្រី	-	ពេញមួយឆ្នាំ
៣៦	ដំរទឹក	-	ពេញមួយឆ្នាំ
៣៧	វល្លិផ្តៅ	-	ពេញមួយឆ្នាំ

Draft

តារាង៥.៣.១១៖ បង្ហាញអំពីប្រភេទផលអនុផលព្រៃឈើប្រភេទឱសថបុរាណ

ល.រ	ឈ្មោះក្នុងតំបន់	ឈ្មោះឡាតាំង	ផ្នែកដែលប្រើប្រាស់	កបនឹងជំងឺ
១	ទឹកដោះខ្លាតូច	*Holarrhena curtisii*	ឬស , ដើម	បង្កើនទឹកដោះ,ជំនួយសរសៃ
២	វល្លិ៍ធ្មេញត្រី	*Bridelia cambodiana*	រុក្ខជាតិទាំមូល	ឬសដូងបាត,ផ្សះ
៣	វល្លិ៍ដោះគន់	*Tetraceara sarnebtosa*	រុក្ខជាតិទាំងមូល	បង្កើនទឹកដោះ
៤	ត្របែកព្រៃ	*Lagerstroemia floribunda jack*	ឬស,ដើម,សំបក	គ្រុនពោះវៀន,រាគមួល
៥	សាវម៉ាវព្រៃ	*Passiflora foetida linn*	ទាំងមូល	បញ្ចុះកំដៅ, ងងុយដេក
៦	ឆ្កែស្រែង	*Cananga latifolia*	ឬស	គ្រុន,ឬសដូងបាត
៧	ងប់	*Sauropus androgynus*	ស្លឹក, ឬស, ដើម	បញ្ចុះទឹកនោម
៨	ស្គៅ	*Azadirachla indica*	សំបក	ថ្នាំក្រពះ
៩	កណ្តាប់ចង្អេរ	*Pouzolzia zeylenica*	មែក, ស្លឹក	មហារីក
១០	មុខឈ្នាង	*Pouzolzia zeylanica (linn) benn*	រុក្ខជាតិទាំងមូល	ក្អកធ្លាក់ឈាម,ក្អកទូទៅ
១១	ឆ្មារ	*Acacia intsia*	សំបក	ក្រពះ
១២	វល្លិ៍ត្រដិត	*Cayratia trifolia (linn)domin*	ស្លឹក, ដើម, ឬស	សត្វពិសខាំ, គ្រុនក្តៅ
១៣	គ្រើល	*Melanorrihoea laccifera , Pierre.*	ឬស	គ្រុនចាញ់
១៤	គគីរ	*Hopea odorata, Roxb.*	សំបក,សាច់ឈើ,ជ័រ	គ្រុនចាញ់,ឃាត់ឈាម,ដំបៅ
១៥	សង្ឃ្រ័	*Zizyphus oenoplia mill*	សំបក	គ្រុនក្តៅ, ក្រពះ, ពោះវៀន
១៦	ឈើភ្លើង	*Diospyros nitida*	ស្លឹក, ឬស	គ្រាំ, ស្លឹកស្រពន់, ដូរមិនទៀង
១៧	ច្រែស	*Albizia lebbeck, (L) Benth.*	សំបក, ឬស	គ្រុន, ឈឺសន្លាក់ដៃជើង
១៨	គោមួយ	*Evonymus cochinchinensis*	ដើម, សំបក	ផ្សះស្បូន,ជំនួយសរសៃ,
១៩	ខ្លែងពណ៌	*Banhinia bassacensis pierre*	ដើម, ឬស	ពុលអាហារ
២០	កុមារពេជ្រ (មើម)	*Stephania Sp*	មើម	បញ្ចុះកំដៅ, ជំនួយសរសៃប្រសាទ
២១	ទេពពិរ៉ូ	*Cinnamomum cambodianum*	សំបក	ស្លាក់ខ្យល់, ជំនួយអាហារ
២២	បញ្ញើក្អែក	*Loranthus sp*	ទាំងមូល	ក្អក , ឈឺសន្លាក់ដៃជើង

ល.រ	ឈ្មោះក្នុងតំបន់	ឈ្មោះឡាតាំង	ផ្នែកដែលប្រើប្រាស់	កបនឹងជំងឺ
២៣	ខ្នុរព្រៃ	*Artocarpus asperula,* Gagn	ខ្លឹម,ស្លឹក,ផ្លែ	ក្សោគក៌, ឈឺថ្លើម
២៤	បេង	*Afzelia xylocarpa, (Kurz) Craib.*	សំបក, ឬស, ខ្លឹម ,គ្រាប់	ជំនួយកំលាំង,បួស,ឡើងឈាម
២៥	ធ្នង់	*Pterocarpus macrocarpus, Kurz.*	ស្លឹក,សំបក,ខ្លឹម	រាគ,គ្រុន,ពុល
២៦	ត្រាត្រាវ	*Fagraea fragrans, Roxb.*	ខ្លឹម,ស្លឹក	បន្ទន់លាមក,បំបាត់រមាស់
២៧	ត្រយឹង	*Diospyros helferi, C.B.Clarke*	ផ្លែ, ស្លឹកខ្ចី, សំបក	របេង,ធ្លាក់ស,រាក,ឬសដូងបាត
២៨	កណ្ដោល	*Careya arborea*	ផ្លែ, សំបក	រាគមួល(ផ្លែ) មហារីក(សំបក)
២៩	គ្រញូង	*Dalbergia cochinchinensis, Pierre*	សំបក	ត្រជាក់,ធ្លាក់ស
៣០	កំរើកគុម្ព	*Spirolabium cambodianum*	ឬស, ដើម	ជំនួយកំលាំង, ជំនួយសរសៃ,បាក់
៣១	ជើងគោ	*Bauhiniia malabarica roxb*	ស្លឹក, សំបក, ឬស	ក្អក
៣២	នាងនួន	*Dalbergia barriensis, Pierre*	សំបក	ត្រជាក់, ធ្លាក់ស, ហើម,
៣៣	ត្រសេក	*Peltophorum dasyrachis*	ឬស, សំបក	ផ្សះពិស, គ្រុនក្តៅ, រាគមួល
៣៤	គ្រាច	*Dipterocarpus intricatus, Dyer.*	ខ្លឹម, សំបក	ជំនួយកំលាំង, រាក, ផ្សះថ្លើម
៣៥	ផ្ចឹក	*Shorea obtusa, Woll.*	ជ័រ,ខ្លឹម,សំបក,ឬស	ជំនួយសុខភាព,ធ្លាក់ស,ពន្យាកំនើត
៣៦	សុក្រំ	*Xylia dolabriformis, Benth*	ខ្លឹម,សំបក,ផ្លែ,ផ្កា	ទល់លាមក,គ្រាំ,បញ្ចុះកំដៅ
៣៧	កកោះ	*Sindora cochinchinensis, Baill.*	សំបក, គ្រាប់	រាក,បួស,រោគសើស្បែក
៣៨	ក្រឡាញ់	*Dialium Cochinchinansis, Pierre*	សំបក	រាក
៣៩	ចន្ទន៍ក្រស្នា	*Aquiaria crassna, Pierre*	សាច់ឈើ,ខ្លឹម ក្រអូប,ប្រេង,ឬស	ដើរខ្យល់,សន្លាក់ដៃជើង,ហើម, រលាកតំរងនោម
៤០	ចំរៀក	*Albizia corniculata*	សំបក, ឬស	រាក, ឈឺស្បូន, ធ្លាក់ស
៤១	ត្បែង	*Dipterocarpus obtusifolius, Teysm.*	ជ័រ, សំបក, ស្លឹក	ឈឺធ្មេញ,រាក,កមរមាស់,ផ្សះរបួស

ល.រ	ឈ្មោះក្នុងតំបន់	ឈ្មោះឡាតាំង	ផ្នែកដែលប្រើប្រាស់	កបនឹងជំងឺ
៤២	ស្រឡៅ ឬតន្ទនេល	*Lagerstroemia sp*	សំបក	រាករូស
៤៣	ពពាលខែ	*Alstonia scholaris (L.)R. Br.*	សំបក	រាកមួល, ជំនួយកំលាំង
៤៤	ធ្លក	*Parinarium annamensis, Hance*	សំបក	ធ្លាក់ស,ខ្ចាំឈាម,ហើម
៤៥	ចំបក់	*Irvingia malayana Oliv,ex Benn.*	សំបក, ស្លឹក	ផ្សះដំបៅ, រាក
៤៦	សំព័រ	*Artocarpus semperyirens*	ផ្លែ, សំបក, ឬស	ក្អក, រាក, ឈឺក

យោងទៅតាមលទ្ធផលនៃការសម្ភាសជាមួយប្រជាជននៅក្នុងតំបន់ដូចជា អ្នកដងច្បាក់ជ័រទឹក អ្នករកផលអនុផលព្រៃឈើ ប្រជាជនដែលធ្វើស្រែចំការ អ្នកធ្វើការជួញដូរផលអនុផលព្រៃឈើ និងបុគ្គលិកកម្មករបច្ចុប្បន្នយើងអាចធ្វើការវាយតម្លៃស្ថានភាពជាក់ស្តែងអំពីវត្តមាននៃប្រភេទផលអនុផលព្រៃឈើដែលមាននៅក្នុងនឹងក្បែរទីតាំងតំបន់គម្រោង បើប្រៀបធៀបនឹង ៥ឆ្នាំមុន(តារាង៥.១២ និងតារាង៥.១៣)៖

តារាង៥.៣.១២៖ លទ្ធផលនៃការវាយតម្លៃស្ថានភាពប្រភេទផលអនុផលព្រៃឈើ

ល.រ	ឈ្មោះខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	មតិរបស់ប្រជាជន(សម្ភាសន៍)
១	ក្លួច	*Dioscorea hispida Denn*	នៅមានមធ្យម
២	ដំឡូងទៀន	*Dioscorea brevipetiolata Prain & Burkill*	នៅមានមធ្យម
៣	ដំឡូងជ្រូក	*Dioscorea oryzetorum*	នៅមានមធ្យម
៤	ដំឡូងទឹក	*Dioscorea pentaphylla L.*	នៅមានមធ្យម
៥	រំដេង	*Alpinia galangal*	នៅមានមធ្យម
៦	ចុងផ្តៅ	-	នៅមានមធ្យម
៧	ត្រួយរាំង	*Barringtonia acutangula*	នៅមានមធ្យម
៨	ផ្តាចាហួយ	*Curcuma alismatifolia*	នៅមានមធ្យម
៩	ទំពាំង	-	សំបូរ
១០	ស្លឹកព្រិច	*Melienthes suavis*	នៅមានមធ្យម
១១	ត្រួយប៉ប្រើស	*Smilax glabra*	នៅមានមធ្យម
១២	ត្រួយល្មៀង	*Cratoxylum formosum subsp.formosum*	សំបូរ

Draft

ល.រ	ឈ្មោះខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	មតិរបស់ប្រជាជន(សម្ភាសន៍)
១៣	ផ្សិតប៉ក់	-	សំបូរ តាមឆ្នាំ
១៤	ផ្សិតឈើ	-	សំបូរ តាមឆ្នាំ
១៥	ផ្សិតកញ្ចោ	-	សំបូរ តាមឆ្នាំ
១៦	ផ្សិតក្ងោក	-	សំបូរ តាមឆ្នាំ
១៧	ផ្លៃគុយ	*Willughbeia edulis*	នៅមានមធ្យម
១៨	ផ្លៃសិរមាន់	*Nephelium hypoleucum*	នៅមានតិចតួច
១៩	ផ្លៃក្ងៀវ	*Baccaurea ramiflora Lour*	នៅមានមធ្យម
២០	ផ្លៃពង្រ	*Schleicheria trijuga Willd.*	នៅមានតិចតួច
២១	ផ្លៃម៉ាកព្រេង	-	នៅមានតិចតួច
២២	ផ្លៃម៉ាកប្រាំង	*Bouea oppositifolia*	នៅមានមធ្យម
២៣	ផ្លៃព្រីង	*Syzygium lineatum Blum*	នៅមានមធ្យម
២៤	ផ្លៃព្រួស	*Garcinia ferrea Pierre*	នៅមានតិចតួច
២៥	ផ្លៃជន្លួស	-	នៅមានតិចតួច
២៦	ផ្លៃកន្ធតព្រៃ	*Phyllandthus emblica L.*	នៅមានមធ្យម
២៧	ឃ្មុំ	-	នៅមានមធ្យម
២៨	ហ៊ីង	-	នៅមានមធ្យម
២៩	ឫស្សី	-	សំបូរគួរសមដែរ
៣០	គីង្គក់	-	នៅមានមធ្យម
៣១	ដំរចុង	-	នៅមានមធ្យម
៣២	ជើមរុន	-	នៅមានមធ្យម
៣៣	ប្រស្វា	-	សំបូរតាមឆ្នាំ
៣៤	ចុងស្តៅ	-	នៅមានមធ្យម
៣៥	វល្លិ៍ថ្នឹង	-	សំបូរ
៣៥	ជើមធ្មេញត្រី	-	នៅមានមធ្យម
៣៦	ដំរទឹក	-	នៅមានមធ្យម
៣៧	វល្លិ៍ផ្តៅ	-	នៅមានមធ្យម

Draft

តារាង៥.៣.១៣ ៖ លទ្ធផលនៃការវាយតម្លៃស្ថានភាពប្រភេទផលអនុផលព្រៃឈើ

ល.រ	ឈ្មោះក្នុងតំបន់	ឈ្មោះឡាតាំង	ផ្នែកដែលប្រើប្រាស់	មតិរបស់ប្រជាជន(សម្ភាសន៍)
១	ទឹកដោះខ្លាតូច	*Holarrhena curtisii*	ឫស , ដើម	សំបូរ
២	វល្លិ៍ធ្មេញត្រី	*Bridelia cambodiana*	រុក្ខជាតិទាំមូល	នៅមានបង្គួរ
៣	វល្លិ៍ដោះគន់	*Tetraceara sarnebtosa*	រុក្ខជាតិទាំងមូល	សំបូរ
៤	ត្រែបែកព្រៃ	*Lagerstroemia floribunda jack*	ឫស,ដើម,សំបក	សំបូរ
៥	សារម៉ាវព្រៃ	*Passiflora foetida linn*	ទាំងមូល	សំបូរ
៦	ឆ្កែស្រែង	*Cananga latifolia*	ឫស	សំបូរ
៧	ងប់	*Sauropus androgynus*	ស្លឹក, ឫស, ដើម	នៅមានមធ្យម
៨	ស្តៅ	*Azadirachla indica*	សំបក	សំបូរ
៩	កណ្តាប់ចង្អេរ	*Pouzolzia zeylenica*	មែក, ស្លឹក	សំបូរ
១០	មុខឈ្នាង	*Pouzolzia zeylanica (linn) benn*	រុក្ខជាតិទាំងមូល	នៅមានមធ្យម
១១	ធ្នារ	*Acacia intsia*	សំបក	សំបូរ
១២	វល្លិ៍ត្រជិត	*Cayratia trifolia (linn)domin*	ស្លឹក, ដើម, ឫស	សំបូរ
១៣	គ្រើល	*Melanorrihoea laccifera , Pierre.*	ឫស	សំបូរ
១៤	គគីរ	*Hopea odorata, Roxb.*	សំបក,សាច់ឈើ,ដំរ	សំបូរ
១៥	សង្ឃ្រ	*Zizyphus oenoplia mill*	សំបក	សំបូរ
១៦	ឈើក្លឹង	*Diospyros nitida*	ស្លឹក, ឫស	សំបូរ
១៧	ច្រេស	*Albizia lebbeck, (L) Benth.*	សំបក, ឫស	សំបូរ
១៨	គោមួយ	*Evonymus cochinchinensis*	ដើម, សំបក	សំបូរ
១៩	ខ្លែងពណ៌	*Banhinia bassacensis pierre*	ដើម, ឫស	សំបូរ
២០	កុមារពេជ្រ (មើម)	*Stephania Sp*	មើម	សំបូរ
២១	ទេពពិរ៉ូ	*Cinnamomum cambodianum*	សំបក	សំបូរ
២២	បញ្ញើក្អែក	*Loranthus sp*	ទាំងមូល	សំបូរ
២៣	ខ្នុរព្រៃ	*Artocarpus asperula,* Gagn	ខ្ចឹម,ស្លឹក,ផ្លែ	សំបូរ

ល.រ	ឈ្មោះក្នុងតំបន់	ឈ្មោះឡាតាំង	ផ្នែកដែលប្រើប្រាស់	មតិរបស់ប្រជាជន(សម្ភាសន៍)
២៤	បេង	*Afzelia xylocarpa, (Kurz) Craib.*	សំបក, ឬស, ខ្លឹម,គ្រាប់	នៅមានមធ្យម
២៥	ធ្នង់	*Pterocarpus macrocarpus, Kurz.*	ស្លឹក,សំបក,ខ្លឹម	នៅមានមធ្យម
២៦	ត្រាត្រាវ	*Fagraea fragrans, Roxb.*	ខ្លឹម,ស្លឹក	នៅមានមធ្យម
២៧	ត្រយឹង	*Diospyros helferi, C.B.Clarke*	ផ្លែ, ស្លឹកខ្ចី, សំបក	នៅមានមធ្យម
២៨	កណ្តោល	*Careya arborea*	ផ្លែ, សំបក	សំបូរ
២៩	គ្រញូង	*Dalbergia cochinchinensis, Pierre*	សំបក	នៅមានមធ្យម
៣០	កំរើកគុម្ព	*Spirolabium cambodianum*	ឬស, ដើម	មានតិចតួច
៣១	ជើងគោ	*Bauhiniia malabarica roxb*	ស្លឹក, សំបក, ឬស	សំបូរ
៣២	នាងនួន	*Dalbergia barriensis, Pierre*	សំបក	នៅមានមធ្យម
៣៣	ត្រសេក	*Peltophorum dasyrachis*	ឬស, សំបក	មានការថយចុះ ០០%
៣៤	គ្រាច	*Dipterocarpus intricatus, Dyer.*	ខ្លឹម, សំបក	សំបូរ
៣៥	ផ្ចឹក	*Shorea obtusa, Woll.*	ជ័រ,ខ្លឹម,សំបក,ឬស	នៅមានមធ្យម
៣៦	សុក្រំ	*Xylia dolabriformis, Benth*	ខ្លឹម,សំបក,ផ្លែ,ផ្កា	នៅមានមធ្យម
៣៧	កកោះ	*Sindora cochinchinensis, Baill.*	សំបក, គ្រាប់	នៅមានមធ្យម
៣៨	ក្រឡាញ់	*Dialium Cochinchinansis, Pierre*	សំបក	នៅមានមធ្យម
៣៩	ចន្ទន៍ក្រស្នា	*Aquiaria crassna, Pierre*	សាច់ឈើ,ខ្លឹមក្រអូប, ប្រេង,ឬស	មានតិចតួច
៤០	ចំរៀក	*Albizia corniculata*	សំបក, ឬស	សំបូរ
៤១	ត្បែង	*Dipterocarpus obtusifolius, Teysm.*	ជ័រ, សំបក, ស្លឹក	សំបូរ
៤២	ស្រឡៅ ឬ ឥន្ធនេល	*Lagerstroemia sp*	សំបក	សំបូរ
៤៣	ពពាលខែ	*Alstonia scholaris (L.)R. Br.*	សំបក	សំបូរ

Draft


ល.រ	ឈ្មោះក្នុងតំបន់	ឈ្មោះឡាតាំង	ផ្នែកដែលប្រើប្រាស់	មតិរបស់ប្រជាជន(សម្ភាសន៍)
៤៤	ធ្លក	*Parinarium annamensis, Hance*	សំបក	សំបូរ
៤៥	ចំបក់	*Irvingia malayana Oliv,ex Benn.*	សំបក, ស្លឹក	សំបូរ
៤៦	សំព័រ	*Artocarpus semperyirens*	ផ្លែ, សំបក, ឬស	សំបូរ

រូបភាព៥.៣.១៖ ប្រភេទផលអនុផលព្រៃឈើនៅក្នុង និងក្បែរទីតាំងតំបន់គម្រោង



ដើមដំរទឹក(ដើមគ្រាច)


ផ្តាចាហួយអ្នកភូមិយកមក


ទឹកឃ្មុំដែលអ្នកភូមិរកបាន


ដំរចុង


ដំរទឹកដែលប្រមូលបាន


ផ្ទៃតរបស់ឃ្មុំ


ដើមគ្រាច(ប្រើជាឱសថ)


ដើមកកោះ(ប្រើជាឱសថ)


ដើមកផ្ទឹក(ប្រើជាឱសថ)

៥.៤.៣. ទំនាស់ដីធ្លី

បន្ថែមពីលើផលប៉ះពាល់ដែលនឹងអាចកើតមានលើធនធានព្រៃឈើដែលប្រជាជនអាស្រ័យផល ព្រៃសហគមន៍ ព្រៃបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ព្រៃអារក្ស ផ្នូរខ្មោចបុរាណ និងប្រភពទឹកធម្មជាតិ ដំណើរការកំណត់ព្រំដីរបស់ក្រុមហ៊ុន បានបង្កឲ្យមានផលប៉ះពាល់ដីស្រែ-ចំការ ជាពិសេសចំការរំលដុំរបស់គ្រួសារមួយចំនួន។ កន្លងមក ក្រុមហ៊ុនបានដោះស្រាយផលប៉ះពាល់ដីលំនៅដ្ឋានជូនប្រជាជន ប៉ុន្តែដីមួយចំនួននៅមិនទាន់ដោះស្រាយអស់រួចរាល់ ដោយក្រុមហ៊ុនចោទថាប្រជាជនទន្ទ្រានលើដីរបស់ក្រុមហ៊ុនដែលបានសម្បទានរួចហើយ។ ផ្ទុយទៅវិញ ប្រជាជនបានចោទថាក្រុមហ៊ុនយកដីរបស់ពួកគាត់ ធ្វើឲ្យពួកគាត់គ្មានដីធ្វើស្រែ និងដីបម្រុងទុកសម្រាប់កូនចៅ

ជំនាន់ក្រោយ ដែលបញ្ហានេះកើតមានចំពោះប្រជាជននៅក្នុងឃុំប៉ង់ ឃុំហាតប៉ក់ ឃុំតាឡាត និងឃុំក្នុំកុកដែលមានពីរភូមិគឺភូមិកាឡែសាពួន និងភូមិទៀមក្រោម។ ក្នុងកិច្ចពិគ្រោះយោបល់ជាសាធារណៈ (សូមអានជំពូកទី៦) ប្រជាជន និងអាជ្ញាធរភូមិ-ឃុំ នៅតែអះអាងថា ប្រជាជនមិនមានដីសម្រាប់ធ្វើស្រែចំការ និងដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ

ទោះជាលោកនាយកគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុនបានអះអាងថា ក្រុមហ៊ុនបានកាត់ដីធ្លីប៉ះពាល់ទាំងនេះចេញរួចហើយដើម្បីបញ្ចប់ជម្លោះ។ លើសពីនេះ កំណត់ហេតុនៃកិច្ចប្រជុំ ស្តីពីកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត កាលពីថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១៤ បានបញ្ជាក់ដែរថា ក្នុងកិច្ចដំណើរការវាស់វែង និងចុះបញ្ជីដីធ្លី (ដែលមានការចូលរួមទាំងពីអាជ្ញាធរឃុំ និងភូមិផងនោះ) ក៏មិនមានប្រជាពលរដ្ឋណាមកតវ៉ា ឬទាមទារដីធ្លីដែលទទួលរងផលប៉ះពាល់នោះទេ។

បើផ្អែកតាមការពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាជនផ្ទាល់ ផ្ទៃដីគម្រោងដែលទទួលបាននេះនៅជាប់ពាក់ព័ន្ធនឹងដីធ្លីរបស់ប្រជាជន និងសហគមន៍ជនជាតិដើមភាគតិចមួយចំនួនទៀតដូចបង្ហាញក្នុងតារាង៥.១៤។


តារាង៥.៣.១៤៖ ដីធ្លីដែលប្រជាជនអះអាងថាមិនទាន់បានដោះស្រាយ (គិតត្រឹមថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦)

ឃុំ	ភូមិ	ដីធ្លីដែលប្រជាជនអះអាងថាមិនទាន់បានដោះស្រាយ
ប៉ង់	ប៉ង់	ដីចម្ការវិលជុំ
	ហ្វាំង	ដីចម្ការវិលជុំ ដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ
តាឡាត	រំពាត់	ដីចម្ការវិលជុំ ព្រៃអាស្រ័យផល ប្រភពទឹកធម្មជាតិ និងផ្នែកខ្លះនៃផ្លូវខ្មោចដូនតា ដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ដីសហគមន៍ជនជាតិដើមភាគតិចដែលក្នុងនោះមានដូចជា៖ ដីចម្ការវិលជុំ ព្រៃអាស្រ័យផល ទីវាលសម្រាប់ចិញ្ចឹមគោ-ក្របី
	តាឡាត	ដីសហគមន៍ជនជាតិដើមភាគតិចដែលក្នុងនោះមានដូចជា៖ ដីចម្ការវិលជុំ ព្រៃអាស្រ័យផល ទីវាលសម្រាប់ចិញ្ចឹមគោ-ក្របី ដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ

កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរខេត្តរតនគិរី អាជ្ញាធរខេត្តស្ទឹងត្រែង និងសហគមន៍ជនជាតិដើមភាគតិចភូមិរំពាត់ ក្នុងការចុះធ្វើការផ្ទៀងផ្ទាត់ និងបោះបង្គោលព្រំ ដើម្បីបញ្ចប់បញ្ហាទំនាស់ដីធ្លីដែលកើតមានឡើងដោយសារភាពមិនច្បាស់លាស់នៃព្រំប្រទល់ខេត្តទាំងពីរ ក៏ដូចជាព្រំប្រទល់ដីសហគមន៍ជនជាតិដើមភាគតិចភូមិរំពាត់ដែលស្ថិតនៅក្នុងខេត្តស្ទឹងត្រែង (ទីតាំងគម្រោងស្ថិតនៅក្នុងខេត្តរតនគិរី)។ សូមមើលកំណត់ហេតុស្តីពីការប្រជុំត្រួតពិនិត្យបោះបង្គោលព្រំប្រទល់រវាង ភូមិបីត្រពាំងក្រហម ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី និងភូមិរំពាត់ ឃុំតាឡាត ស្រុកសេសាន ខេត្តស្ទឹងត្រែង ក្នុងឧបសម្ព័ន្ធ។

ផ្អែកតាមការពិភាក្សាជាមួយមេឃុំប៉ង់ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ផ្ទៃដីគម្រោងក្នុងអនុតំបន់ទី៤ (ផែនទី៥.៣.១) ស្ទើរតែទាំងស្រុងត្រូវបានប្រជាពលរដ្ឋ កាប់ទន្ទ្រានធ្វើជាកម្មសិទ្ធរបស់ខ្លួន។

ផែនទី៥.៣.១៖ ទីតាំងដីដែលប្រជាជនបានកាប់ទន្ទ្រានធ្វើកម្មសិទ្ធិ




តាមផ្លូវច្បាប់គម្រោងនេះមិនមានបញ្ហាដីធ្លីដែលមិនទាន់បានដោះស្រាយនោះទេ ពីព្រោះផ្ទៃដីពាក់ពន្ធ័ត្រូវបានកាត់ចេញពីទីតាំងវិនិយោគរួចហើយ ដូចបង្ហាញក្នុងផែនទី៤.២។ ផ្ទៃដីគម្រោងដែលក្រុមហ៊ុនទទួលបានក្នុងពេលបច្ចុប្បន្ន (៦៥០៩,២៧ ហិកតា) ត្រូវបានចេញបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ លើ ១០ភ្ជាលដី មាន ១០បណ្ណ ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនគិរី ដូចភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ។

៥.៤.៤. អនាម័យ និងសុខភាព

៥.៤.៤.១. ការប្រើប្រាស់ទឹក

សុខភាពអនាម័យ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងប្រភពទឹកប្រើប្រាស់។ ទិន្នន័យដែលបានមកពីការសម្ភាសប្រជាជនផ្ទាល់បង្ហាញថា គ្រួសារប្រជាជនប្រមាណ ៦៦% ប្រើប្រាស់ទឹកភ្លៀងសម្រាប់ធ្វើស្រែចំការនៅរដូវវស្សា ដោយឡែក នៅរដូវប្រាំងគឺពួកគាត់ប្រើប្រាស់ទឹកព្រែក អូរ ប្រឡាយ និងទឹកអណ្តូងសម្រាប់ធ្វើស្រែចំការ និងមានការប្រើប្រាស់ទឹកទន្លេតិចតួច។ បន្ថែមពីលើនេះទៀត ប្រជាជនដែលបានផ្តល់សម្ភាសន៍ ៤៨%បានប្រើប្រាស់ទឹកទន្លេសម្រាប់ប្រើប្រាស់ប្រចាំនៅក្នុងផ្ទះ ដូចជាបោកគក់សំលៀកបំពាក់ ងូត និងដាំស្លដាដើម និង៣២% បានប្រើប្រាស់ទឹកអណ្តូង។ ដូច្នេះប្រភេទទឹកទន្លេនឹងទឹកក្រោមដីបានក្លាយជាប្រភពទឹកសំខាន់សម្រាប់ការប្រើប្រាស់ប្រចាំនៅក្នុងផ្ទះ។


ក្រាហ្វិចទី៥.៣.១២៖ ប្រភពទឹកប្រើប្រាស់របស់ប្រជាជនឃុំពាក់ព័ន្ធ



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភានិងធ្នូ ឆ្នាំ២០១៦)

លទ្ធផលបង្ហាញឲ្យឃើញថា ប្រជាជនជិតពាក់កណ្តាលនៃចំនួនប្រជាជនសរុបដែលត្រូវបានជ្រើសរើសសម្រាប់ការផ្តល់បទសម្ភាសន៍ យល់ឃើញថាទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរមានគុណភាពមិនល្អ ដូចជាមានកករល្អក់ មានក្លិនស្អុយ មានសំរាម។ល។ ដែលធ្វើឲ្យពួកគាត់គ្មានទំនុកចិត្តក្នុងការយកមកប្រើប្រាស់។ ប្រសិនបើគម្រោងអនុវត្តន៍ពេញលេញ ហើយ មិនមានវិធានការត្រឹមត្រូវក្នុងការទប់ស្កាត់ការបំពុលប្រភពទឹកពីថ្នាំគីមីដែលបាញ់ទៅលើដំណាំកសិ-ឧស្សាហកម្មរបស់គាត់នោះ ករណីនេះអាចនឹងប្រហែលជាភាគរយនៃប្រជាជនដែលមិនប្រើប្រាស់ទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃកើនឡើងច្រើនជាង៤១%នៃចំនួនបច្ចុប្បន្ន។យ៉ាងណាមិញ មានប្រជាជនត្រឹមតែ៤%ប៉ុណ្ណោះដែលយល់ឃើញថាទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរមានបរិមាណមិន គ្រប់គ្រាន់សម្រាប់ពួកគាត់ប្រើប្រាស់ដែលតម្រូវឲ្យគាត់ប្រើប្រាស់ប្រភពទឹកផ្សេងជំនួសវិញ។


ក្រាហ្វិចទី៥.៣.១៣៖ ទស្សនៈប្រជាជនចំពោះមូលហេតុដែលមិនប្រើទឹកទន្លេ ស្ទឹង ព្រែកឬអូរប្រើប្រាស់ប្រចាំថ្ងៃ



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភានិងធ្នូ ឆ្នាំ២០១៦)

ដោយឡែក បើយើងក្រឡេកមកមើលអំពីមូលហេតុដែលប្រជាជនមិនប្រើប្រាស់ទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរសម្រាប់ធ្វើស្រែចំការវិញ ក្រាហ្វិក៥.១៤ បង្ហាញឱ្យឃើញថាប្រជាជនដែលបានផ្តល់សម្ភាសន៍៥១%យល់ឃើញថា ទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរនៅឆ្ងាយពីចំការដែលធ្វើឱ្យពួកគាត់មិនប្រើប្រាស់សម្រាប់ធ្វើស្រែចំការ។ ដោយឡែក ហេតុផលមួយទៀតដែលពួកគាត់បានលើកឡើងគឺការធ្វើស្រែចំការ គឺធ្វើតែមួយម្តងក្នុង១ឆ្នាំ ដូច្នេះ ពួកគាត់ពឹងផ្អែកទៅលើទឹកភ្លៀងសម្រាប់ប្រើប្រាស់ដែលមានអត្រាអ្នកឆ្លើយចំនួន៤៤%នៃចំនួនសំណាកសរុប។ ផ្ទុយទៅវិញ ប្រជាជនចំនួនត្រឹមតែ៥%ប៉ុណ្ណោះដែលយល់ឃើញថាបរិមាណ ទឹកទន្លេ ទឹកស្ទឹង ទឹកព្រែកឬទឹកអូរមិន គ្រប់គ្រាន់សម្រាប់ប្រើប្រាស់។


ក្រាហ្វិច៥.៣.១៤៖ ទស្សនៈប្រជាជនចំពោះមូលហេតុដែលមិនប្រើទឹកទន្លេ ស្ទឹង ព្រែកឬអូរប្រើប្រាស់សម្រាប់ធ្វើស្រែចំការ



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភា និងធ្នូ ឆ្នាំ២០១៦)

ក្រាហ្វិក៥.១៥ បង្ហាញពីទស្សនៈប្រជាជនចំពោះគុណភាពទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរ ។ ភាគរយនៃអ្នកដែលបានសម្ភាសន៍ចំនួន៤៣%យល់ឃើញប្រភពទឹកទាំងនោះថាមានភាពល្អក់កករ ២៤%យល់ឃើញថាមានសំរាមច្រើន និង១៣%យល់ឃើញថាមានក្លិនមិនល្អ។ ដោយឡែក ប្រជាជនចំនួន២០%យល់ឃើញថាគុណភាពទឹកល្អអាចប្រើប្រាស់បាន។ យើងសង្កេតឃើញថា អត្រានៃចំនួនប្រជាជនក្នុងតំបន់សិក្សាប្រមាណ៨០%យល់ឃើញថាគុណភាពទឹកមិនអាចទទួលយកបាន បញ្ហានេះគួរបង្កើនការប្រុងប្រយ័ត្នពេលដែលគម្រោងសម្បទានមួយនេះដំណើរការ។

ក្រាហ្វិច៥.៣.១៥៖ ស្ថានភាពគុណភាពទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរ



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភា និងធ្នូ ឆ្នាំ២០១៦)

ដោយឡែក បើយើងធ្វើការប្រៀបធៀបគុណភាពទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរ ក្នុងរវាង៥ប្រាំមុន តារាង៥.១៤ បង្ហាញថា អ្នកផ្តល់សម្ភាសន៍ចំនួនច្រើនរហូតដល់៧០% យល់ឃើញថា គុណភាពទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរប្រែជាល្អក់កកនិងកខ្វក់ជាងមុន ក្នុងនោះ២២%យល់ឃើញថាដោយសារប្រជាជនក្នុងតំបន់ចោលកាកសំណល់ក្បែរប្រភពទឹក ២០%យល់ឃើញថាលំហូរចូលនៃទឹកកខ្វក់និងសំរាមមកពីខ្សែទឹកខាងលើ ១៦%យល់ឃើញថា ចំនួនប្រជាជននៅក្នុងភូមិមានការកើនឡើង និង១៦%លំហូរចូលនៃទឹកកខ្វក់និងកាកសំណល់ជីគីមីមកពីគម្រោងអភិវឌ្ឍន៍នានា។ ករណីនេះដែរ គម្រោងត្រូវមានការប្រុងប្រយ័ត្នខ្ពស់ពេលចាប់ដំណើរការពេញលេញ ដោយសារស្ថានភាពគុណភាពទឹកត្រូវបានបំពុលស្រាប់ពីបណ្តាគម្រោងអភិវឌ្ឍន៍ផ្សេងៗ។ជាមួយគ្នាដែរ ២១%នៃអ្នកផ្តល់សម្ភាសន៍យល់ឃើញថាមិនប្រែប្រួលទេក្នុងរវាងបច្ចុប្បន្ននិង៥ប្រាំមុន។ ទោះជាយ៉ាងណាមានអ្នកផ្តល់សម្ភាសន៍ចំនួន៩%ឆ្លើយថាមិនបានសង្កេតអំពីបញ្ហានេះ។

តារាង៥.៣.១៥៖ បម្រែបម្រួលគុណភាពទឹកទន្លេ ទឹកស្ទឹង ទឹកព្រែក ឬទឹកអូរ ប្រៀបធៀបជាមួយ៥ឆ្នាំមុន


គុណភាពទឹកប្រៀបធៀបជាមួយនឹង ៥ឆ្នាំមុន	ចំនួនគិតជាភាគរយ	មូលហេតុនៃបម្រែបម្រួល	ចំនួនគិតជាភាគរយ
មិនប្រែប្រួល	21%		
ប្រែជាល្អក់កករ និងកខ្វក់ជាងមុន	70%	ចំនួនប្រជាជននៅក្នុងភូមិមានការកើនឡើង	16%
		ប្រជាជនក្នុងតំបន់ចោលកាកសំណល់ក្បែរប្រភពទឹក	22%
		លំហូរចូលនៃទឹកកខ្វក់និងកាកសំណល់ជីគីមីមកពីគម្រោងអភិវឌ្ឍន៍នានា	12%

		លំហូរចូលនៃទឹកកខ្វក់ និងសំរាមមកពីខ្សែទឹកខាងលើ	20%
មិនបានសង្កេត	9%		

ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភា និងធ្នូ ឆ្នាំ២០១៦)

ជាមួយគ្នាផងដែរ ក្រាហ្វិច៥.១៦ បង្ហាញអំពីលទ្ធផលនៃបរិមាណទឹកទន្លេ ទឹកស្ទឹង ព្រែកឬអូរប្រៀបធៀបនឹង៥ឆ្នាំមុន ដែលក្នុងនោះប្រជាជនមានចំនួន៦៦% យល់ឃើញថាបរិមាណទឹកទន្លេ ទឹកស្ទឹង ព្រែកឬអូរមានតិចជាងមុន ជាពិសេសនៅរដូវប្រាំង ដែលនេះគឺជាការព្រួយបារម្ភមួយដែរនៅពេលគម្រោងនេះចាប់ដំណើរការត្រឹមត្រូវ។ ដោយឡែក ប្រជាជន២១%យល់ឃើញថាមិនប្រែប្រួល និង១៣%ឆ្លើយថាមិនបានសង្កេត។


ក្រាហ្វិច៥.៣.១៦៖ បរិមាណទឹកទន្លេ ទឹកស្ទឹង ព្រែកឬអូរប្រៀបធៀបនឹង៥ឆ្នាំមុន



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភា/ធ្នូ ឆ្នាំ២០១៦)

ក្រាហ្វិច៥.១៧ បង្ហាញអំពីលទ្ធផលនៃបម្រែបម្រួលកម្រិតអណ្តូង ប្រៀបធៀបនឹង៥ឆ្នាំមុន។ លទ្ធផលបង្ហាញថាប្រជាជនក្នុងតំបន់សិក្សាចំនួន៣០% បានផ្តល់ចម្លើយថានៅក្នុងភូមិរបស់គាត់មិនមាន អណ្តូងប្រើប្រាស់ទេ។ ដោយឡែក ប្រជាជនក្នុងតំបន់សិក្សាចំនួន៧០% ឆ្លើយថាក្នុងភូមិដែលគាត់រស់នៅមាន អណ្តូងសម្រាប់ប្រើប្រាស់ ជាពិសេសនៅក្នុងចំនួននោះ ប្រជាជន២៣%យល់ឃើញថាកម្រិតទឹកធ្លាក់ទាបជាងមុនខ្លាំង ២០%យល់ឃើញថាធ្លាក់ចុះទាបជាងមុន តិចតួច។ ផ្ទុយទៅវិញ ៣% យល់ថាកម្រិតទឹកឡើងខ្ពស់ជាងមុនខ្លាំង និងមានតែ១%យល់ថាកម្រិតទឹកឡើងខ្ពស់ជាងមុនតិចតួច។ ក្នុងនោះដែរ ១៦%យល់ឃើញថាមិនប្រែប្រួល និងមានប្រជាជនដែលផ្តល់បទសម្ភាសន៍ត្រឹម៧%ដែលឆ្លើយថាមិន បានសង្កេត។ តួលេខនេះក៏ជាករណីមួយគួរបារម្ភដោយសារប្រជាជនសរុបប្រមាណ៤៣%យល់ថា កម្រិតទឹកមានការប្រែប្រួលធ្លាក់ចុះជាងមុនខ្លាំងនិងតិចតួច។

ក្រាហ្វិច៥.៣.១៧៖ បម្រែបម្រួលកម្រិតទឹកអណ្តូងប្រៀបធៀបនឹង៥ឆ្នាំមុន



ប្រភព៖ អង្កេតសេដ្ឋកិច្ច-សង្គមក្នុងតំបន់សិក្សា (ខែឧសភា និងធ្នូ ឆ្នាំ២០១៦)

៥.៤.៤.២. ការប្រើប្រាស់បង្គន់

តាមរយៈទិន្នន័យស្ថានភាពស្ថិតិឃុំឆ្នាំ២០១៥ និងការអង្កេតជាក់ស្តែង ប្រជាជនក្នុងតំបន់គម្រោងមិនមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់ក្នុងគ្រួសារឡើយ ដោយសារចំណេះដឹងពីអនាម័យរបស់ពួកគាត់នៅមានកម្រិត។ ការបន្ទោរបង់ពាសវាលពាសកាល បង្កឲ្យបាត់បង់សោភ័ណភាពបរិស្ថាន និងជាប្រភពចម្លងជម្ងឺដល់មនុស្ស និងសត្វពាហនៈផងដែរ។ ជាក់ស្តែង នៅក្នុងឃុំប៉ង់មានគ្រួសារចំនួន១៧.១% ឃុំភ្នំកុកមានគ្រួសារចំនួន ៩% ឃុំហាតប៉ក់ចំនួន ១៦.៨% និងឃុំតាឡាតមានចំនួន៥.៨%ដែលមានបង្គន់អនាម័យប្រើប្រាស់។ ក្នុងនោះមានតែគ្រួសារចំនួន ៦.៤% ក្នុងឃុំប៉ង់ និង៨.៣% ក្នុងឃុំភ្នំកុក និងឃុំតាឡាតមាន៥.៨% និងចំនួនច្រើនជាងគេនៅក្នុងឃុំហាតប៉ក់១៦.៨%មានបង្គន់អនាម័យដែលមានបច្ចេកទេសសម្រាប់ប្រើប្រាស់។ ទិន្នន័យក៏បង្ហាញផងដែរពីចំនួនគ្រួសារដែលមានប្រភពទឹកជិតជាង១៥០ម៉ែត្រពីផ្ទះ ក្នុងនោះមានតែឃុំហាតប៉ក់មានចំនួនគ្រួសារប្រមាណ៤.៩% និងឃុំតាឡាតដែលមានចំនួនច្រើនគួរសមគឺ១៣.៩%ប៉ុណ្ណោះ ឯឃុំប៉ង់និងឃុំភ្នំកុកស្ទើរតែមិនមានគ្រួសារដែលមានប្រភពទឹកជិតជាង១៥០ម៉ែត្រពីផ្ទះទេ។

តារាង៥.៣.១៦៖ ភាគរយគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់

បរិយាយ	ឃុំប៉ង់	ឃុំភ្នំកុក	ឃុំហាតប៉ក់	ឃុំតាឡាត
ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់	104	64	62	52
ចំនួនគ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស	39	59	62	49
%គ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស	6.4	8.3	16.8	5.5
%សរុបគ្រួសារមានបង្គន់អនាម័យប្រើប្រាស់	17.1	9.0	16.8	5.8
ចំនួនគ្រួសារមានប្រភពទឹកជិតជាង១៥០ម៉ែត្រពីផ្ទះ	0	1	18	124
%គ្រួសារមានប្រភពទឹកជិតជាង១៥០ម៉ែត្រពីផ្ទះ	0.0	0.1	4.9	13.9


ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

៥.៤.៤.៣. សុខភាព

សុខភាព គឺជាបញ្ហាប្រឈមចម្បងក្នុងការរស់នៅរបស់ប្រជាជនក្នុងតំបន់សិក្សា ដែលជាតំបន់ដាច់ស្រយាល និងជាតំបន់ខ្ពង់រាបសម្បូរទៅដោយព្រៃ។ ប្រជាជនជានិច្ចជាកាលតែងតែជួបប្រទះការលំបាក ក្នុងការស្វែងរកសេវាសុខភាព ដោយស្ថិតនៅឆ្ងាយពីតំបន់ទីប្រជុំជន កត្តាផ្លូវគមនាគមន៍ និងកត្តាជីវភាព។ ប្រជាជនភាគច្រើនទៅមណ្ឌលសុខភាពភ្នំកុក ក្នុងករណីធ្ងន់ធ្ងរកើតឡើងប្រជាជនត្រូវទៅដល់មណ្ឌលសុខភាពរុនសៃ និងទៅរកសេវានៅតាមគ្លីនិកតាមផ្ទះ សម្រាប់អ្នកដែលមានលទ្ធភាព។

ក្រាហ្វិក៥.១៨ បង្ហាញថា ក្នុងចំណោមករណីនៃប្រភេទជម្ងឺដែលកើតមានញឹកញាប់ ជម្ងឺគ្រុនចាញ់ស្រាលកើតមានឡើងតែចំពោះមនុស្សវ័យកណ្តាល (១៥-៤៩ឆ្នាំ) ហើយការរងរបួសដោយគ្រោះថ្នាក់ចរាចរណ៍ក្រៅពីប៉ះទង្គិចក្បាល និងជម្ងឺរលាកផ្លូវដង្ហើមលើ ក៏កើតឡើងភាគច្រើនចំពោះមនុស្សវ័យនេះដែរ។ ដោយឡែក ជម្ងឺរាគ ជម្ងឺរាគមូល ជម្ងឺរលាកផ្លូវដង្ហើមក្រោម ជម្ងឺភ្នែក និងជម្ងឺសើស្បែក កើតមានឡើងក្នុងសមាមាត្រប្រហាក់ប្រហែលគ្នារវាងមនុស្សវ័យកណ្តាល និងកូនក្មេង (0-៤ឆ្នាំ)។ គួរឱ្យកត់សម្គាល់ថា វ័យដែលស្ថិតក្នុងភាពងាយរងគ្រោះគឺពី 0-៤ឆ្នាំ និង១៥-៤៩ឆ្នាំ។

ក្រាហ្វិច៥.៣.១៨៖ ចំនួនករណីប្រភេទជំងឺកើតតាមវ័យ ក្នុងឆ្នាំ២០១៥



ប្រភព៖ ទិន្នន័យពីមណ្ឌលសុខភាពភ្នំកុក

ក្នុងចំណោមប្រភេទជម្ងឺដែលកើតមាន ជម្ងឺរាគ និងរាគមូល អាចបណ្តាលមកពីការរស់នៅខ្វះអនាម័យ ការបរិភោគអាហារខ្វះអនាម័យ និងការបរិភោគបន្លែប្រើប្រាស់ថ្នាំគីមី។ កត្តាទាំងនេះ អាចមានការពាក់ព័ន្ធការបាត់បង់ព្រៃឈើ ដែលមានតួនាទីជានិយ័តករទឹក និងជាប្រភពអាហារធម្មជាតិ។

៥.៤.៤.៣. វិស័យទេសចរណ៍

នៅក្នុងតំបន់សិក្សា មិនមានតំបន់ដែលមានសក្តានុពលទេសចរណ៍ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍នោះទេ លើកលែងតែតំបន់ទេសចរណ៍តូចតាចសម្រាប់ការកំសាន្តរបស់ប្រជាជនមូលដ្ឋានប៉ុណ្ណោះ។ តំបន់ទេសចរណ៍តូចតាចទាំងនេះ មានដូចជា អូរ ស្ទឹង ព្រៃកដែលមានទឹកធ្លាក់បន្តិចបន្តួច និងអាស្រមក្នុរបស់ប្រជាជនជនជាតិដើមភាគតិចប៉ុណ្ណោះ។

៥.៤.៥. សម្បត្តិវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី

ដូចមានបង្ហាញក្នុងតារាង ៥.១៦ ប្រជាជននៅក្នុងឃុំពាក់ព័ន្ធទាំង០៤ (ឃុំប៉ង់ ឃុំក្នុំកុក ឃុំហាតប៉ក់ និងឃុំតាឡាត) ភាគច្រើនជាជនជាតិដើមភាគតិច (លន់ គ្រឹងនិងព្រៅ)។ ជនជាតិលន់ មានរស់នៅច្រើនតែក្នុងឃុំប៉ង់ និងឃុំក្នុំកុក។ ជនជាតិគ្រឹងមានរស់នៅច្រើននៅឃុំក្នុំកុក ឃុំហាតប៉ក់ ឃុំតាឡាតនិងចំនួនតិចតួចនៅឃុំប៉ង់។ ជនជាតិព្រៅ មានរស់នៅច្រើនក្នុងឃុំក្នុំកុក និងមានជនជាតិទំពូនតិចតួចប៉ុណ្ណោះរស់នៅក្នុងឃុំប៉ង់ និងឃុំហាតប៉ក់។ ក្នុងកំឡុងពេលឆ្នាំ២០១៤-២០១៥ ចំនួនគ្រួសារប្រជាជនជនជាតិដើមភាគតិចក្នុងឃុំទាំង០៤នេះ មានការប្រែប្រួលតិចតួចប៉ុណ្ណោះ ប៉ុន្តែចំនួនជនជាតិគ្រឹង មានការប្រែប្រួលគួរកត់សម្គាល់គឺពី ៤៣៤នាក់ (៤0% នៃប្រជាជនសរុប) ក្នុងឆ្នាំ២០១៤ ទៅ ៦៨៥នាក់ (៤៤% នៃប្រជាជនសរុប)។

តារាង៥.៣.១៧៖ ស្ថិតិប្រជាជនជនជាតិដើមភាគតិចក្នុងឃុំពាក់ព័ន្ធ

បរិយាយ		ឃុំប៉ង់		ឃុំក្នុំកុក		ឃុំហាតប៉ក់		ឃុំតាឡាត	
		2014	2015	2014	2015	2014	2015	2014	2015
ប្រជាជន	ជនជាតិទំពូន	10	10	0	0	7	7	0	0
	ជនជាតិការ៉ែត	14	3	0	0	0	0	0	0
	ជនជាតិលន់	462	462	388	441	0	0	0	0
	ជនជាតិគ្រឹង	4	10	434	685	22	102	171	230
	ជនជាតិព្រៅ	0	0	376	376	0	0	0	0
	ចំនួនជនជាតិសរុប	490	485	1198	1502	29	109	171	230
	%ជនជាតិសរុប	15%	16%	40%	44%	2%	9%	15%	19%
គ្រួសារ	ជនជាតិទំពូន	3	8	0	0	3	4	0	0
	ជនជាតិការ៉ែត	3	2	0	0	0	0	0	0
	ជនជាតិលន់	10	10	100	100	0	0	0	0
	ជនជាតិគ្រឹង	2	3	121	120	11	14	76	78
	ជនជាតិព្រៅ	0	0	100	100	0	0	0	0
	ចំនួនជនជាតិសរុប	18	23	321	320	14	18	76	78
	%ជនជាតិសរុប	3%	4%	43%	42%	6%	7%	25%	25%

ប្រភព៖ ទិន្នន័យស្តីពីស្ថានភាពឃុំឆ្នាំ២០១៥

Draft

ព្រៃអារក្ស ផ្នូរដូនតា ការសែនព្រេន និងទីតាំងស្ថាននីយ៍បុរាណជាដើម មានសារៈសំខាន់ណាស់សម្រាប់ប្រជាជនជនជាតិដើមភាគតិចទាំងនេះ ព្រោះវាបង្ហាញពីវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ដែលជាអត្តសញ្ញាណដើមរបស់ពួកគាត់ពីដូនតាមក ហើយវាក៏ជាកន្លែងសក្ការៈបូជារបស់ពួកគាត់ជាច្រើនជំនាន់មកដែរ។ ការកាប់បំផ្លាញព្រៃអារក្ស ធ្វើឲ្យប៉ះពាល់ដល់ការគោរពបូជារបស់ជនជាតិដើមភាគតិច។ តាមការសម្ភាសន៍ជាមួយនឹងលោកមេឃុំហាតប៉ក់បានឲ្យដឹងថា ទីទួលសុវត្ថិភាព ព្រៃអារក្ស គឺបានកាត់ចេញឱ្យប្រជាជនអស់ហើយ។ ក្នុងករណីការប៉ះពាល់ទៅលើវប្បធម៌ប្រពៃណីដូនតានៅក្នុងគម្រោងសម្បទានមួយនេះ ហាក់មិនមានបញ្ហាចោទធ្ងន់ធ្ងរនោះទេ។

ចំពោះការស្លៀកពាក់វិញ យើងសង្កេតឃើញថា ជនជាតិដើមភាគតិចទាំងអស់បានផ្លាស់ប្តូរប្រពៃណីនៃការស្លៀកប៊ឹង មកស្លៀកសំលៀកបំពាក់ដូចប្រជាជនខ្មែរដែរ។ ពួកគាត់ស្លៀកពាក់ប៊ឹងតែពេលមានពិធីបុណ្យប្រពៃណីម្តងម្កាលតែប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ការផ្លាស់ប្តូរប្រពៃណីនេះ បានកើតមានឡើងតាំងពីមុនពេលមានគម្រោងនេះមកម្ល៉េះ។

៥.៥. សន្និដ្ឋាន

ការសិក្សាពីបរិស្ថានរូបសាស្ត្រ បង្ហាញថា៖

- ភូគព្ភសាស្ត្រ៖ តំបន់គម្រោងគ្របដណ្តប់ដោយមានសិលាមេចំនួន ០៨ ប្រភេទគឺ៖ Basalt, Basaltic Plateau deposits, Calcareous rock, Floodplains, Non Classified rock, Red Terrace (red sandstone) ឬ reddish brown sandstone, Rhyolite, និងPediments។
- សណ្ឋានដី, កម្រិតជម្រាល និងការហូរច្រោះ៖ តំបន់គម្រោងមានរយៈកម្ពស់ជាមធ្យមប្រែប្រួលក្នុងចន្លោះ ៩០ ទៅ ១០០ម៉ែត្រធៀបនឹងនីវ៉ូទឹកសមុទ្រ ហើយជាទូទៅមានសណ្ឋានដីរាបស្មើរដែលមានកម្រិតជម្រាលប្រមាន ០ ទៅ ៣ ដឺក្រេ ដែលជាលក្ខណៈសណ្ឋានដីដែលមិនប្រឈមនឹងការសឹករេចរឹល និងការហូរច្រោះឡើយ។
- ប្រភេទដី និងគុណភាពដី៖ តំបន់គម្រោងគ្របដណ្តប់ដោយដីចំនួន៣ ប្រភេទគឺ Acid Lithosols, Grey hydromorphics, និងPilnthite podzols ដែលជាដីដែលមានលក្ខណៈសមស្របសម្រាប់ធ្វើកសិកម្ម។ ចំពោះគុណភាពដី នាពេលបច្ចុប្បន្ន គុណភាពដីនៅក្នុងតំបន់គម្រោងគឺមានភាពល្អធម្មតា និងមិនមានវត្តមានសារធាតុបំពុលណាដែលគួរឲកត់សម្គាល់ឡើយ។
- គុណភាពខ្យល់ សំឡេង និងរំញ័រ៖ នាពេលបច្ចុប្បន្ន ស្ថានភាពគុណភាពខ្យល់នៅក្នុងតំបន់គម្រោងគឺមានស្ថានភាពល្អធម្មតា កំហាប់នៃប៉ារ៉ាម៉ែត្រសំខាន់ៗដូចជា CO, NO_2, SO_2, TSP, និងPM10 គឺស្ថិតនៅក្នុងកម្រិតស្តង់ដារ។ ចំពោះ ឡេង និងរំញ័រ នាពេលបច្ចុប្បន្នពុំមានសកម្មភាពណាមួយដែលបង្កឲមានសម្លេង ឬរំញ័រដែលបង្កជាការរំខាននោះទេ។
- ប្រព័ន្ធដលសាស្ត្រ និងគុណភាពទឹក៖ ក្រៅពីទន្លេសេសាន នៅក្នុងតំបន់គម្រោងមានប្រព័ន្ធផ្លូវទឹកសំខាន់ៗចំនួន ០៧គឺ៖ អូរភ្នំ, អូរតាង, ពាមមាត់អូរ, អូរតាឡាត, អូរដរិក អូរស្វាយរៀង និងអូរកន្សែង (ជាអូរសំខាន់ជាងគេ ព្រោះជាប្រភពទឹក និងជាកន្លែងគោរពបូជារបស់ប្រជាជនក្នុងតំបន់)។ គុណភាពទឹក ទាំងទឹកលើដី និងក្រោមដី ជាទូទៅគឺមានស្ថានភាពល្អធម្មតា និងមិនមានវត្តមានសារធាតុបំពុលអ្វី (pollutants) គួរឲ្យកត់សម្គាល់ឡើយ។

ការសិក្សាពីធនធានជីវសាស្ត្រ បង្ហាញថា៖

- តំបន់ការពារធម្មជាតិ និងអភិរក្សជីវៈចម្រុះ៖ នៅក្នុងបរិវេណក្បែរៗ តំបន់គម្រោងពុំមានវត្តមាននៃតំបន់ការពារធនធានធម្មជាតិ និងជីវៈចម្រុះឡើយ។ តំបន់ការពារដែលនៅជិតទីតាំងគម្រោងបំផុត គឺ

ឧទ្យានជាតិ វ៉ឺនសៃសៀមប៉ាង ដែលស្ថិតនៅចម្ងាយប្រមាណ ១២គីឡូម៉ែត្រពីទីតាំងគម្រោង ដូច្នេះ ហើយវត្តមាននៃគម្រោងនឹងមិនបង្កផលប៉ះពាល់ដោយផ្ទាល់ចំពោះតំបន់នោះទេ។

- ធនធានព្រៃឈើ៖ នៅក្នុងទីតាំងគម្រោងនាពេលបច្ចុប្បន្ន មានផ្ទៃដីគម្របព្រៃឈើសរុបប្រមាណ ៥.២៦៤,៦១ ហិកតា ស្មើនឹង ៨៣,៥% នៃផ្ទៃដីគម្រោងសរុប ក្នុងនោះមានព្រៃស្រោង (៥៤៩,១១ ហិកតា), ព្រៃពាក់កណ្តាលស្រោង (៣៩៣,១៦ ហិកតា) និងព្រៃល្បោះ (៥.២១៦,៣២ ហិកតា)។ នៅពេលគម្រោងចាប់ផ្តើមដំណើរការ ស្ទើរតែទាំងអស់នៃផ្ទៃដីគម្របព្រៃនេះនឹងត្រូវបំលែងជាផ្ទៃសម្រាប់ដាំដំណាំ និងផ្ទៃសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័នគម្រោង។
- ធនធានសត្វព្រៃ៖ វត្តមានរបស់សត្វព្រៃនៅក្នុង និងក្បែរទីតាំងគម្រោងសរុបទាំងអស់មានចំនួនប្រមាណ ៣៥១ប្រភេទ ដែលក្នុងនោះ ថនិកសត្វមានចំនួន ៥៣ប្រភេទ, លូន/ឧរង្គសត្វ មានចំនួន ៩៤ប្រភេទ, និងបក្សី មានចំនួន ២០៤ប្រភេទ។បើយោងតាមប្រកាសលេខ ក.ស.ក ២០០៧ ក្នុងចំនោមសត្វព្រៃទាំង ៣៥១នោះ ប្រភេទដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ (EN) មាន ១២ប្រភេទ, ប្រភេទមានដោយកម្រ (R) មាន ៤០ប្រភេទ, ប្រភេទមានដោយបង្គួរ (C)នាម ២៩៦ប្រភេទ និងប្រភេទមិនទាន់ចាត់ថ្នាក់ (NA) មាន៣ប្រភេទ។ សត្វព្រៃទាំងនេះនឹងរងផលប៉ះពាល់ពីសកម្មភាពគម្រោងដោយផ្ទាល់ នឹងដោយប្រយោល។
- ធនធានមច្ឆជាតិ៖ នៅក្នុង និងក្បែរតំបន់គម្រោងមានវត្តមាន មច្ឆជាតិចំនួន ២៤៣ប្រភេទ ដែលក្នុងនោះមានពពួកវាំរីសត្វចំនួន ១១ប្រភេទ។ យោងតាមអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ក្នុងចំនោមមច្ឆជាតិទាំង ២៤៣ប្រភេទនោះ ប្រភេទជិតផុតពូជ (EN) មាន ៩ ប្រភេទ, ប្រភេទកំពុងរងគ្រោះថ្នាក់ (CR) មាន ៤ ប្រភេទ, ប្រភេទងាយរងគ្រោះថ្នាក់ (VU) មាន ៣ ប្រភេទ, និងប្រភេទមិនទាន់បានចាត់ថ្នាក់ជាប្រភេទផល ផលិតផលដលផល ដែលកំពុងរងគ្រោះថ្នាក់ (NA) មាន ២២៧ ប្រភេទ។ មច្ឆជាតិទាំងនេះនឹងរងផលប៉ះពាល់ពីសកម្មភាពគម្រោងនៅពេលគម្រោងចាប់ផ្តើមដំណើរការ។

ការសិក្សាពីធនធានសេដ្ឋកិច្ច-សង្គម បង្ហាញថា៖

- ក្នុងតំបន់មានជនជាតិដើមភាគតិចចំនួន ០៥ (ទំពួន គ្រឹង ការ៉ែត លន់ និងព្រៅ) ដែលគោរពបូជាអារក្សអ្នកតា ហើយមួយចំនួនតូចប៉ុណ្ណោះជាជនជាតិខ្មែរដែលគោរពព្រះពុទ្ធសាសនា។
- ប្រជាជនក្នុងតំបន់ស្ទើរទាំងអស់មានលំនៅដ្ឋានចំនួន២កន្លែង ដែលមួយជាលំនៅដ្ឋាននៅក្នុងភូមិ និងមួយទៀតជាលំនៅដ្ឋាននៅតាមស្រែ-ចំការរបស់គាត់។ ប្រជាជនមានទម្លាប់រស់នៅក្នុងផ្ទះ ក្នុងភូមិក្រោយរដូវច្រូតកាត់រួច ឬនៅរដូវប្រាំង និងរស់នៅក្នុងផ្ទះតាមស្រែ-ចំការនៅក្នុងរដូវដាំដុះ ឬរដូវវស្សា។ ចំពោះប្រភេទផ្ទះ និងទំហំផ្ទះ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នារវាងផ្ទះនៅក្នុងភូមិ និងផ្ទះនៅតាមស្រែ-ចំការ។ ភាគច្រើននៃផ្ទះទាំងនោះជាប្រភេទផ្ទះធ្វើពីឈើប្រក់សង្កសី។
- ប្រជាពលរដ្ឋនៅក្នុងតំបន់សិក្សា ធ្វើការប្រកបរបរចិញ្ចឹមជីវិតដោយពឹងផ្អែករលើរបរក្នុងវិស័យកសិកម្ម (ដូចជា ការដាំស្រូវវស្សា ការចិញ្ចឹមសត្វ ការនេសាទជាដើម) សេវាកម្ម (លក់ដូរ ជាងជួសជុល) និងការងារបានប្រាក់កម្រៃប្រចាំថ្ងៃឬខែ (ស៊ីឈ្នួល/កម្មករតាមចំការ កម្មកររោងចក្រ បម្រើការរាជការ) ជាដើម។ ក្នុងចំណោមមុខរបរទាំងនេះ មុខរបរចំបងមាន៣ប្រភេទ ដែលក្នុងនោះមុខរបរចំបង២ប្រភេទស្ថិតក្នុងវិស័យកសិកម្ម៖ ការធ្វើស្រែវស្សារហូតដល់ទៅជិត៦០% ការធ្វើស្រូវនិងចំការប្រមាណ២០% និងមុខរបរចំបងទី៣ស្ថិតនៅក្នុងវិស័យ សេវាកម្មគឺការលក់ដូរមានភាគរយប្រមាណ១០%។ មុខរបរចំបងទាំង៣នេះត្រូវបានប្រជាជនទទួលស្គាល់ថាជាមុខរបរដែលផ្តល់ប្រាក់ចំណូលប្រចាំ ហើយបន្ថែម

ពីលើមុខរបរចំបងទាំងបីនេះ មានមុខរបរ៤ផ្សេងទៀតដែលមិនមែនជាមុខរបរចំបងរបស់ប្រជាជន តែត្រូវបានពួកគាត់ពឹងផ្អែកនឹងចាត់ទុកថាជាមុខរបរដែលផ្តល់ប្រាក់ចំណូលដល់ពួកគាត់ផងដែរ។ មុខរបរទាំងនោះមានដូចជា ការចិញ្ចឹមគោក្របី និងការចិញ្ចឹមមាន់ ទានិងជ្រូក ការធ្វើចំការដំឡូងមី ការធ្វើចំការ ស្វាយចន្ទី។ ការងារនៅក្នុងវិស័យកសិកម្មគឺជាប្រភេទការងារចំបង និងជាការងារដែលចូលរួមផ្តល់ប្រាក់កម្រៃដល់ពួកគាត់ច្រើនជាងការងារនៅក្នុងវិស័យផ្សេងៗទៀត។ ចំពោះមុខរបរក្នុងវិស័យកសិកម្ម ប្រជាជនអាចរកប្រាក់ចំណូលបានប្រមាណជាមធ្យម ៦៨២ដុល្លារអាមេរិក/ឆ្នាំ/គ្រួសារ (ឬ ៥៦,៨ដុល្លារ/ខែ/នាក់)។

- ប្រជាជនក្នុងមួយគ្រួសារមានមុខរបរច្រើន អាចចាប់ពីពីរឡើងទៅ ដូច្នេះចំពោះចំណូលក្នុងផ្នែកការងារទទួលបានកម្រៃ មុខរបរផ្តល់ប្រាក់ចំណូលច្រើនជាងគេបំផុត គឺមុខរបរលក់ ដូរគ្រឿងទេស (២៩២៤ ដុល្លារ/ឆ្នាំ/គ្រួសារ) (ឬ២៤៣,៦ដុល្លារ/ខែ/នាក់)។ ចំណែកឯមុខរបរដែល ផ្តល់ប្រាក់ចំណូលខ្ពស់បន្ទាប់គួរឲ្យកត់សម្គាល់ដែរនោះ គឺមុខរបរក្នុងវិស័យសេវាកម្ម មានដូចជា ស៊ីឈ្នួលជាដើម ដែលជាប្រាក់ចំណូលមួយថេរ (ជាមធ្យម ១,២៩៩ ដុល្លារ/ឆ្នាំ/គ្រួសារ) (ឬ ១០៨,២៥ដុល្លារ/ខែ/នាក់)។

- ការប្រៀបធៀបរវាងចំណូល និងចំណាយ បញ្ជាក់ឲ្យឃើញថា លក្ខខណ្ឌសេដ្ឋកិច្ចក្នុងតំបន់សិក្សា នៅអាចទ្រទ្រង់ដល់ជីវភាពប្រចាំថ្ងៃបានក្នុងពេលបច្ចុប្បន្ន។ ទោះជាយ៉ាងនេះក្តី គ្រួសារដែលចំណាយចាប់ពី ៨០% នៃចំណូលសរុបឡើងទៅ អាចប្រឈមនឹងបញ្ហាជីវភាព ប្រសិនបើធនធានធម្មជាតិដែលពួកគាត់អាស្រ័យផល (ដូចជា ព្រៃឈើ និងប្រព័ន្ធអូរធម្មជាតិ) នៅតែបន្តរេចរឹល ហើយពួកគាត់មិនអាចរក ឬពង្រីកមុខរបរ បន្ថែមនោះទេ។

- មុខរបរធ្វើស្រែ និងធ្វើចំការ មានសារៈសំខាន់ជាងមុខរបរផ្សេងទៀតសម្រាប់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់សិក្សា ហើយកម្រិតសារៈសំខាន់នៃមុខរបរទាំងពីរនេះមានការថយចុះសរុបពី ៥១% នៅមុនពេល មានគម្រោង ទៅ៤៨%ក្នុងពេលបច្ចុប្បន្ន។ កម្រិតសារៈសំខាន់នៃមុខរបរចិញ្ចឹមសត្វ និងមុខរបរផ្សេងទៀតមាន ដូចជាលក់ដូរជាដើម (ក្រៅពីរកអនុផលព្រៃឈើ ប្រមូលផលឈើ និងនេសាទ) មានការកើនឡើងបន្តិចបន្តួច នៅមុននិងក្រោយមានគម្រោង។ ដោយឡែក កម្រិតសារៈសំខាន់នៃមុខរបររកអនុផលព្រៃឈើមានការធ្លាក់ចុះពី ២២% នៅមុនពេលមានគម្រោង មកត្រឹម១៥% ក្នុងពេលបច្ចុប្បន្ន ខណៈដែលមុខរបរនេសាទចំពោះ ប្រជាជនក្នុងភូមិនៃតំបន់សិក្សាមានការធ្លាក់ចុះសារៈសំខាន់តិចតួច ២-៦%។បម្រែបម្រួលយុទ្ធសាស្ត្រនៃការ ប្រកបរបរចិញ្ចឹមជីវិតដើម្បីឆ្លើយតបនឹងស្ថានភាពនៃការអភិវឌ្ឍក្នុងតំបន់ បានធ្វើឲ្យគ្រួសារប្រមាណជា៣ក់កណ្តាល នៃចំនួនសំណាកដែលបានសម្ភាសន៍ (៥១%) មានកម្រិតជីវភាពកើន ឡើង។ ដោយឡែក គ្រួសារប្រមាណ ២០% មានកម្រិតជីវភាពថយចុះ និងគ្រួសារប្រមាណ ២៣% មានកម្រិតជីវភាពនៅដដែល។

- ទោះបីស្ថានភាពសេដ្ឋកិច្ច និងសង្គមក្នុងតំបន់កំពុងមានការប្រែប្រួលទៅតាមរបត់សង្គម ក៏ទំនៀមទំលាប់ របស់ជនជាតិដើមភាគតិចសំខាន់ៗក្នុងតំបន់នៅរក្សាបានមួយចំនួនធំដូចជា៖ ប្រពៃណីគោរពព្រៃអារក្ស ការការពារ ព្រៃបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយ ការរក្សាព្រៃសម្រាប់កប់សាកសព ការសែនព្រេនពេលមានសមាជិក គ្រួសារឈឺថ្កាត់នានា ពេលមុននិងក្រោយពេលប្រមូលផលស្រូវ ឬ ជំណាំចំការនានា និងការប្រារព្ធនូវពិធី តាមបែបជនជាតិនៅពេលចូលឆ្នាំថ្មី (ធ្វើនៅពេលដូចគ្នានឹង

ជនជាតិខ្មែរ និងមានលក្ខណៈស្រដៀងគ្នា តែខុសគ្នាត្រង់ពួកគាត់មិនទៅវត្ត)។ ដោយឡែក របៀបរបបក្នុងការរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិត មួយចំនួនធំ ត្រូវបានបងប្អូនជនជាតិដើមភាគតិចធ្វើការផ្លាស់ប្តូរហើយ។ ការផ្លាស់ប្តូរទាំងនោះរួមមាន៖ ការចេះធ្វើការលក់ដូរនូវផលិតផល ការចេះដើរស៊ីឈ្នួលគេដើម្បីរកចំណូលចូលគ្រួសារ ចេះកាប់ឈើលក់ ការកាត់បន្ថយនូវរបៀបធ្វើស្រែ និងចំការតាមបែបពនេចរជាដើម។

Draft

ជំពូកទី៦
ការចូលរួមពី
សាធារណជន

ជំពូកទី៦៖ ការចូលរួមពីសាធារណជន

៦.១. សេចក្តីផ្តើម

ការពិគ្រោះយោបល់ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ បានធ្វើឡើងតាមរយៈកិច្ចពិភាក្សាជាលក្ខណៈបុគ្គល និងជាក្រុម ជាមួយស្ថាប័នជំនាញសំខាន់ៗក្នុងខេត្ត អង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានដូចជា៖ អង្គការសង្គ្រោះសត្វព្រៃ (SCW) អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) អង្គការទន្លេបី (3S) អង្គការសមាគមន៍ខ្មែរលើ (HA) និងអង្គការអនុផលព្រៃឈើ (NTFP) អាជ្ញាធរភូមិ-ឃុំ និងសហគមន៍ដែលពាក់ពន្ធ័នានា។ ចំណែកប្រជាជនរស់នៅក្នុងភូមិពាក់ព័ន្ធចំនួន១១រួមមានភូមិប៉ុង ភូមិហ្វាំង ភូមិកាឡែសាពូន ភូមិកាឡែតាវ៉ាង ភូមិភ្នំកុកឡាវ ភូមិកុកព្រៅ ភូមិទៀមក្រោម ភូមិហាតប៉ក ភូមិឡាំប៉ាក់នៃខេត្តរតនគិរី និងភូមិពែត់ និងភូមិតាឡាតនៅខេត្តស្ទឹងត្រែង ក៏ត្រូវបានផ្តល់ឱកាសឱ្យចូលរួមផ្តល់យោបល់តាមរយៈការស្ទង់មតិ/អង្កេតតាមគ្រួសារផងដែរ។ គោលបំណងសំខាន់នៃការពិគ្រោះយោបល់នេះ គឺដើម្បីស្រាវជ្រាវ និងស្វែងយល់ពីផលប៉ះពាល់ជាក់ស្តែងដែលអាចនឹងបង្កឡើងដោយសកម្មភាពគម្រោង វាយតម្លៃពីទស្សនៈរបស់ប្រជាជនចំពោះវត្តមានគម្រោង និងប្រមូលយកនូវក្តីបារម្ភ និងសំណូមពរនានា ដើម្បីជាមូលដ្ឋានក្នុងការកំណត់នូវវិធានការកាត់បន្ថយ។

៦.២. លទ្ធផលនៃកិច្ចពិគ្រោះយោបល់

៦.២.១. កិច្ចពិគ្រោះយោបល់ជាមួយអាជ្ញាធរឃុំ ភូមិ សហគមន៍ និងប្រជាជន

៦.២.១.១ កិច្ចពិគ្រោះយោបល់នៅឃុំភ្នំកុក

- **កិច្ចពិគ្រោះយោបល់ថ្នាក់ឃុំ**

កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង១៤:៣០ នាទីរសៀល ក្រុមការងាររបស់ក្រុមហ៊ុន RCBCC Co., Ltd. បានធ្វើការពិភាក្សាជាមួយមេឃុំភ្នំកុក ក្រុមប្រឹក្សាឃុំ និងមេភូមិពាក់ព័ន្ធ ចំនួន ៥នាក់ (បញ្ជីវត្តមានមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ)។ ការពិភាក្សាបានបង្ហាញឱ្យឃើញថា អាជ្ញាធរមូលដ្ឋានធម្លាប់បានស្គាល់ក្រុមហ៊ុន អេស ខេ ផ្លេនថេសិន ដោយក្រុមការងាររបស់ក្រុមហ៊ុនបានចុះមកសិក្សានិងទំនាក់ទំនងជាមួយមេឃុំជាបន្តបន្ទាប់។ យោងតាមប្រសាសន៍លោកមេឃុំ ក្រុមហ៊ុន អេស ខេ ផ្លេនថេសិនបានចូលមកក្នុងតំបន់នេះតាំងពីឆ្នាំ២០១២មកម្លេះ ប៉ុន្តែមកទល់ពេលបច្ចុប្បន្ន ក្រុមហ៊ុនមិនទាន់បានធ្វើការឈូសឆាយឬប្រតិបត្តិការនៅឡើយទេ។ លើសពីនេះ លោកបានបន្ថែមថា ផ្ទៃដីក្រុមហ៊ុន អេស ខេ ផ្លេនថេសិននេះត្រូវបានស្ថាប័នជំនាញ និងអាជ្ញាធម៌ពាក់ព័ន្ធចុះមកសិក្សានិងកាត់ផ្ទៃដីដែលពាក់ព័ន្ធ នានាដូចជា៖ ផ្ទៃដីសហគមន៍ព្រៃឈើ ផ្ទៃដីតំបន់រក្សាទុក និងដីកប់ខ្មោចជាដើមចេញអស់ហើយ។ ដូច្នេះ បច្ចុប្បន្នមិនមានដីធ្លីជាប់ពាក់ព័ន្ធជាមួយដីប្រជាជនទៀតទេ។ ផ្ទុយទៅវិញ អ្វីដែលជាក្តីបារម្ភនៅក្នុងឃុំភ្នំកុកនេះគឺប្រជាជនអាចនឹងចូលទៅទន្ទ្រានយកដីក្រុមហ៊ុនមកធ្វើស្រែចំការរបស់ពួកគាត់ ដោយក្រុមហ៊ុនមិនទាន់មានដំណើរការ។ ប៉ុន្តែក្នុងចំណោមភូមិចំនួន៥នៅឃុំភ្នំកុកនេះ មានតែភូមិចំនួន២ គឺភូមិកាឡែសាពូននិងភូមិទៀមក្រោមដែលអាចនៅមានបញ្ហាជាមួយដីក្រុមហ៊ុន ព្រោះភូមិទាំងពីរនេះមានព្រំប្រទល់ជាប់នឹងដីក្រុមហ៊ុន។ ។ ក្រៅពីនេះ អាជ្ញាធម៌មិនមានក្តីបារម្ភចំពោះបញ្ហាសន្តិសុខមូលដ្ឋាននៅពេលដែលមានវត្តមានគម្រោងនេះ ពីព្រោះរយៈកាលកន្លងមកស្ថានភាពសន្តិសុខមូលដ្ឋានមានលក្ខណៈល្អប្រសើរទេ។ តំណាងអាជ្ញាធរមូលដ្ឋានបានសម្តែងការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍នេះ ដោយលោកសង្ឃឹមថាគម្រោងអាចជួយលើកកម្ពស់ជីវភាពរបស់ប្រជាជនមូលដ្ឋានតាមរយៈការផ្តល់ការងារបន្ថែម និងជួយធ្វើផ្លូវ ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធខ្លះៗក្នុងឃុំ ដែលនឹង

ជួយឱ្យមានភាពងាយស្រួលក្នុងការធ្វើដំណើរដាងនេះ។ ទោះជាយ៉ាងណា ពួកគាត់បានលើកឡើងនូវក្តីបារម្ភទៅថ្ងៃអនាគតមួយចំនួនដូចខាងក្រោម៖

- ការប៉ះពាល់ដល់ដីប្រជាជននៅពេលក្រុមហ៊ុនចាប់ដំណើរការឈូសឆាយ ដោយសារមិនទាន់មានព្រំប្រទល់នៅទីវាលច្បាស់លាស់
- ការប៉ះពាល់ដល់ការដាងដំរទឹករបស់ប្រជាជននៅពេលក្រុមហ៊ុនអនុវត្តន៍គម្រោងពេញលេញ
- ការបាត់បង់ទីវាលសម្រាប់សត្វពាហនៈដែលប្រជាជនចិញ្ចឹម និងការប្រលែងចោលតាមប្រពៃណីនៅពេលក្រុមហ៊ុនអនុវត្តន៍គម្រោងពេញលេញ
- ប្រជាជនអាចនឹងបាត់បងព្រៃសម្រាប់ប្រមូលផល-អនុផលព្រៃឈើនៅពេលក្រុមហ៊ុនអនុវត្តន៍គម្រោងពេញលេញ

ទន្ទឹមនឹងក្តីបារម្ភទាំងនេះ ពួកគាត់បានលើកឡើងនូវសំណូមពរមួយចំនួនដូចខាងក្រោម ដល់ម្ចាស់ក្រុមហ៊ុនដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមាននៅពេលដែលគម្រោងដំណើរការ៖

- មុនធ្វើការឈូសឆាយ ក្រុមហ៊ុនគួរសិក្សាពីព្រំប្រទល់ដីនៅទីវាលរបស់ប្រជាពលរដ្ឋជិតតំបន់គម្រោងឱ្យបានច្បាស់លាស់
- សូមរក្សាទុកដើមដំរទឹករបស់ប្រជាជនដែលស្ថិតនៅក្នុងតំបន់គម្រោង និងអនុញ្ញាតឱ្យប្រជាជនចូលដងដំរទឹកដូចសព្វដង
- ក្រុមហ៊ុនគួរផ្តល់អាទិភាពឱ្យប្រជាជនមូលដ្ឋានចូលបម្រើការងារនៅពេលគម្រោងដំណើរការ
- នៅពេលដំណើរការគម្រោង ក្រុមហ៊ុនត្រូវធានាថាមិនមានការប៉ះពាល់ដល់ដីចំការរបស់ប្រជាជនដែលកំពុងអាស្រ័យផល។
- នៅពេលដំណើរការគម្រោង ក្រុមហ៊ុនត្រូវមានកិច្ចសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាជនដែលរស់នៅក្បែរទីតាំងគម្រោង។
- គួរមានការបោះបង្គោលព្រំប្រទល់ឱ្យបានច្បាស់លាស់ ជៀសវាងការទន្ទ្រានយកដីគ្នាទៅវិញទៅមក ទាំងពីសំណាក់ប្រជាជន និងក្រុមហ៊ុន។

➢ **កិច្ចពិគ្រោះយោបល់នៅភូមិកាឡែសាពូន**

កិច្ចពិភាក្សានេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ នៅវេលាម៉ោង១៣:៣០នាទី រហូតដល់ម៉ោង១៤:៤៥នាទី នៅផ្ទះរបស់លោកមេភូមិកាឡែសាពូន ដែលមានសមាជិកចូលរួមសរុបចំនួន២២នាក់។

កិច្ចប្រជុំជាមួយប្រជាជននៅក្នុងភូមិកាឡែសាពូនបានបង្ហាញថាប្រជាជនមានក្តីកង្វល់អំពីការបាត់បង់ដីរបស់ពួកគាត់ដោយសារពួកគាត់មិនបានដឹងអំពីគម្រោងវិនិយោគរបស់ក្រុមហ៊ុននេះឡើយ។ លើសពីនេះ ពួកគាត់មានក្តីបារម្ភយ៉ាងខ្លាំងនៅពេលដែលគម្រោងរបស់ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច អេស ខេ ផ្លេនថេសិននេះចាប់ផ្តើមដំណើរការ ពីព្រោះវាអាចនឹងធ្វើឱ្យពួកគាត់បាត់បង់ទីវាលចិញ្ចឹមសត្វ បាត់គោក្របី បាត់បង់ដីកប់ខ្មោច បាត់បង់អនុផលព្រៃឈើ និង បាត់បង់ដីសម្រាប់ កូនចៅជំនាន់ក្រោយៗទៀត។

ឆ្លងតាមកិច្ចប្រជុំពិភាក្សានេះ ប្រជាជនហាក់មិនគាំទ្រឱ្យក្រុមហ៊ុនចូលមកធ្វើការវិនិយោគនៅក្នុងតំបន់នេះទេ។ ប្រសិនបើក្រុមហ៊ុនចុះមកវិនិយោគ ពួកគាត់ សុំឲ្យអាជ្ញាធម៌ភូមិ ឃុំចុះមកធ្វើការចង្អុលបង្ហាញវាស់វែងដីក្រុមហ៊ុនឱ្យបានត្រឹមត្រូវ ដើម្បីឱ្យប្រជាពលរដ្ឋបានដឹងនិងតវ៉ាក្នុងករណីមានប៉ះពាល់ដីប្រជាជន។ ពួកគាត់សំណូមពរឱ្យក្រុមហ៊ុនជូនដំណឹងប្រជាជនជាមុនផង នៅពេលក្រុមហ៊ុនចាប់ផ្តើមដំណើរការឈូសឆាយដី។ ពួកគាត់ក៏បាន

បញ្ជាក់ទៀតថា ក្នុងករណីដែលមានបញ្ហាទំនាស់ដីធ្លីជាមួយប្រជាជននៅក្នុងភូមិ គឺគាត់ស្នើសុំឲ្យម្ចាស់ក្រុមហ៊ុនជួយធ្វើការដោះស្រាយ ឱ្យបានត្រឹមត្រូវនិងប្រកបដោយភាពយុត្តិធម៌។ ជាចុងក្រោយ ពួកគាត់ក៏មានសំណូមពរមួយចំនួនទៀតទៅដល់ក្រុមហ៊ុនដូចជា៖

- ស្នើសុំឲ្យក្រុមហ៊ុនជួយធ្វើផ្លូវចេញចូលភូមិឱ្យបានល្អស្អាត
- ស្នើសុំជួយធ្វើស្ពានឆ្លងកាត់ភូមិឱ្យបានល្អស្អាត
- សុំធ្វើអណ្តូងទឹកសម្រាប់ប្រើប្រាស់នៅក្នុងភូមិ ព្រោះទឹកអូរនាពេលបច្ចុប្បន្នមានបញ្ហាច្រើនណាស់
- ស្នើសុំឱ្យមានការសាងសង់មណ្ឌលសុខភាពមួយកន្លែងនៅក្នុងភូមិ
- សុំឲ្យក្រុមហ៊ុនជួយទុកផ្លូវឱ្យពួកគាត់ចូលទៅធ្វើស្រែចំការ នៅកន្លែងខាងក្នុងនៃផ្ទៃដីគម្រោងដែលបានកាត់ចេញហើយ។

➢ កិច្ចពិគ្រោះយោបល់នៅភូមិទៀមក្រោម

កិច្ចពិភាក្សានេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ នៅវេលាម៉ោង១០:០០ព្រឹកនៅសាលប្រជុំភូមិទៀមក្រោម ដែលមានសមាជិកចូលរួមសរុបចំនួន២០នាក់។ប្រជាជននៅក្នុងភូមិទៀមក្រោម បានបង្ហាញថាពួកគាត់បានស្គាល់នឹងដឹងអំពីគម្រោងនេះ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះក្រុមហ៊ុនមិនទាន់បានធ្វើការវិនិយោគ ឬធ្វើការដាំដុះអ្វីនៅឡើយទេ។ ដូច្នេះពួកគាត់នៅមានកង្វល់ និងមន្ទិលសង្ស័យជាច្រើន ចំពោះបញ្ហាដីធ្លីរបស់ពួកគាត់ដែលកំពុងបង្កបង្កើនផល។ ម្យ៉ាងវិញទៀត ពួកគាត់មានក្តីបារម្ភអំពីការចិញ្ចឹមសត្វ ក៏ដូចជាការអាស្រ័យអនុផលព្រៃឈើ នៅពេលដែលគម្រោងចាប់ផ្តើមដំណើរការ។ ជាពិសេស ពួកគាត់បានបង្ហាញនូវក្តីបារម្ភជាខ្លាំងអំពីការវិនិយោគ នៅលើដីរបស់ក្រុមហ៊ុនដែលគ្របដណ្តប់នៅលើភ្នំលេ ដែលជាទីគោរពសក្ការៈបូជារបស់ពួកគាត់តាមទំនៀមទំលាប់ជនជាតិដើមភាគតិច និងការបាត់បង់ផ្លូវលំដែលពួកគាត់ចេញចូលទៅធ្វើស្រែចំការ។ ដើម្បីកាត់បន្ថយក្តីបារម្ភទាំងនេះ ពួកគាត់បានលើកឡើងនូវសំណូមពរមួយចំនួនទៅកាន់ក្រុមហ៊ុន ដែលមានដូចខាងក្រោម៖

- សូមក្រុមហ៊ុនជួយធ្វើផែនទីជូនគាត់នូវដីស្រែចំការគាត់ (ដែលបានកាត់ចេញហើយ តែមានទីតាំងនៅខាងក្នុងផ្ទៃដីគម្រោង)
- សូមឲ្យក្រុមហ៊ុនជួយធ្វើផ្លូវចេញចូលភូមិរបស់ពួកគាត់ឱ្យបានស្អាតល្អ នៅពេលដែលក្រុមហ៊ុនដំណើរការ
- សូមជួយសាងសង់សាលារៀន និងមណ្ឌលសុខភាពនៅក្នុងភូមិ
- សូមជួយផ្តល់គ្រាប់ពូជសម្រាប់បង្កបង្កើនផល ព្រមទាំងជួយផ្តល់ស្បៀងអាហារនៅពេលដែលប្រជាជននៅក្នុងភូមិជួបគ្រោះមហន្តរាយដោយប្រការណាមួយ
- សូមក្រុមហ៊ុនផ្តល់ដីចាប់ពីពាក់កណ្តាលភ្នំលេ រហូតដល់ភូមិ ដើម្បីទុកឱ្យប្រជាជនធ្វើការចិញ្ចឹមសត្វ ធ្វើស្រែចំការ ព្រមទាំងរកបន្លែផ្លែឈើ
- សូមក្រុមហ៊ុនជួយជីកអណ្តូងទឹកនៅក្នុងភូមិ
- សូមឱ្យក្រុមហ៊ុនធ្វើការបោះបង្គោលឱ្យបានត្រឹមត្រូវនិងច្បាស់លាស់ ដើម្បីឱ្យប្រជាជនបានដឹងអំពីព្រំប្រទល់ដីក្រុមហ៊ុន
- សូមឱ្យក្រុមហ៊ុនរៀបចំសែនព្រេនតាមលក្ខណៈប្រពៃណីរបស់ជនជាតិគាត់ ដែលមានការកាប់ក្របីចាប់ពី២ក្បាលឡើងទៅ មុនពេលដែលក្រុមហ៊ុនរៀបចំធ្វើការឈូសឆាយដីនោះ
- សូមឱ្យក្រុមហ៊ុនជួយធ្វើការដោះស្រាយ និងចេញជាសំណងជូនទៅពួកគាត់ឱ្យបានសមរម្យត្រឹមត្រូវនៅពេលដែលក្រុមហ៊ុនឈូសឆាយប៉ះពាល់ដីធ្លីរបស់ប្រជាជន

- សូមឱ្យក្រុមហ៊ុនធ្វើការជ្រើសរើសប្រជាជននៅក្នុងភូមិជាអាទិភាព នៅពេលដែលក្រុមហ៊ុនត្រូវការជ្រើសរើសបុគ្គលិក ឬកម្មករ ។

៦.២.១.២ កិច្ចពិគ្រោះយោបល់នៅឃុំប៉ង់

➢ កិច្ចពិគ្រោះយោបល់ថ្នាក់ឃុំ

នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ២:០៨នាទីរសៀល ក្រុមការងាររបស់ក្រុមហ៊ុន RCBCC Co., Ltd. បានធ្វើការប្រជុំពិភាក្សាជាមួយមេឃុំប៉ង់ ជំទប់ទី១ និងមេភូមិហ្វាំង មេភូមិប៉ង់ និងអនុភូមិ ដែលចំនួនសរុបចំនួន ០៦នាក់ (បញ្ជីវត្តមានមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ) ។ លទ្ធផលនៃកិច្ចពិភាក្សាបានបង្ហាញថា អជ្ញាធរមូលដ្ឋាននៅឃុំប៉ង់បានស្គាល់ក្រុមហ៊ុន អេស ខេ ផ្លេនថាសិននេះច្បាស់លាស់ដោយហេតុថាពួកគាត់ ធ្លាប់បានចូលរួមសហការធ្វើការងារខ្លះៗជាមួយតំណាងក្រុមហ៊ុន និងបានចូលរួមដោះស្រាយវិវាទរវាងប្រជាជាន និងក្រុមហ៊ុនដោយសា ទីតាំងវិនិយោគរបស់ក្រុមហ៊ុនមានពាក់ព័ន្ធជាមួយដីស្រែរបស់ប្រជាជន។ តំណាងអាជ្ញាធរមូលដ្ឋានបានលើកឡើងថា ក្រុមហ៊ុន អេស ខេ ផ្លេនថាសិនមានវត្តមាននៅឃុំនេះតាំងពីចុងឆ្នាំ២០០៨ ដើមឆ្នាំ២០០៩មកម្ល៉េះ ប៉ុន្តែក្រុមហ៊ុនមិនទាន់ដំណើរការទេដោយសារបញ្ហាដីធ្លីដែលពាក់ព័ន្ធនឹងដីប្រជាជនមិនទាន់ដោះស្រាយរួច។ លោកបានបន្តថាទីតាំងដីរបស់ក្រុមហ៊ុនកាត់ចំក្បាលដីស្រែរបស់ប្រជាជនចំនួន១០០០ហិកតា ក្រោយមកក៏មានក្រុមការងារថ្នាក់ខេត្តចុះសិក្សាកំណត់គោលព្រំដី និងពិនិត្យកាត់ចេញនូវផ្ទៃដីដែលពាក់ព័ន្ធជាមួយដីស្រែចំការរបស់ប្រជាពលរដ្ឋ។ តំណាងអាជ្ញាធរមូលដ្ឋានបានបន្ថែមថា ក្រោយមកទៀតដីស្រែរបស់ប្រជាពលរដ្ឋចំនួន៣០០ហិកតាទៀតនៅមានពាក់ព័ន្ធជាមួយដីរបស់ក្រុមហ៊ុន ហើយដីនេះក៏ត្រូវបានកាត់ចេញប្រហែល៩០%ជាស្ថាពរហើយដោយបន្សល់១០%ជាផ្ទៃដីត្រៀមបម្រុងទុកសម្រាប់កំណើនប្រជាជន។ ប៉ុន្តែតាមការជជែកពិភាក្សា ប្រជាជនយល់ឃើញថាផ្ទៃដី១០%ដែលទុកនេះ មានតែនៅក្នុងផែនទីប៉ុណ្ណោះ ពួកគាត់មិនទាន់បានទទួលដីពិតប្រាកដនៅឡើយទេ។ ដូច្នេះពួកគាត់ទាមទារឱ្យបែងចែកដី១០%នេះឱ្យគ្រួសារដែលគ្មានដីសម្រាប់ធ្វើស្រែចំការប្រើប្រាស់ធ្វើស្រែចំការវិញ ។ យោងតាមប្រសាសន៍លោកមេឃុំ ប្រជាជនប្រហែលជាង១០០គ្រួសារនៅក្នុងឃុំប៉ង់នេះគ្មានដីស្រែចំការហើយពួកគាត់បានវាតទីធ្វើចំការលើដីរបស់ក្រុមហ៊ុន (៥៨គ្រួសារមកពីភូមិហ្វាំង និង៤៥គ្រួសារមកពីភូមិប៉ង់) ដូច្នេះនៅពេលដែលក្រុមហ៊ុនធ្វើការឈូសឆាយនោះ ប្រជាជនអាចនឹងមិនសុខចិត្ត ហើយអាចបង្កឱ្យមានជម្លោះបន្តទៀត ដោយពួកគាត់គ្មានដីពួកគាត់ចង់បានដីដែលគាត់កំពុងធ្វើស្រែចំការមកប្រើប្រាស់។ ប៉ុន្តែលោកបានបញ្ជាក់ថាជាក់ស្តែងដីរបស់ក្រុមហ៊ុនដែលមានប្លង់កម្មសិទ្ធិនោះក៏បានបោះបង្គោលបំពានលើដីប្រជាជនតិចតួចដែរ។

តំណាងអាជ្ញាធរមូលដ្ឋានបានបង្ហាញថាពួកគាត់មិនសូវបារម្ភចំពោះបញ្ហាសន្តិសុខ និងការបាត់បង់ប្រពៃណីនិងវប្បធម៌ ដែលអាចបណ្តាលមកពីជនចំណូលថ្មី នៅពេលដែលមានគម្រោងនេះទេ ហើយក្រុមហ៊ុនក៏មិនទាន់មានការអភិវឌ្ឍអ្វីដែរ ប៉ុន្តែអ្វីដែលជាបញ្ហាចំបងគឺតម្រូវការដីធ្លីសម្រាប់ប្រជាជនដែលគ្មានដីស្រែចំការ និងការចិញ្ចឹមជីវិតរបស់ប្រជាជន ។ ដូច្នេះ ក្តីបារម្ភរបស់អជ្ញាធម៌មូលដ្ឋានមានដូចជា៖

- ការបាត់បង់ព្រៃ និងវាលស្មៅសម្រាប់សត្វពាហនៈនានានៅពេលក្រុមហ៊ុនធ្វើការឈូសឆាយ
- ការបាត់បង់ផល និងអនុផលព្រៃឈើនៅពេលក្រុមហ៊ុនធ្វើការឈូសឆាយព្រៃ
- ការបាត់បង់ផ្លូវសម្រាប់ធ្វើដំណើរ នៅពេលក្រុមហ៊ុនធ្វើការឈូសឆាយ
- ការកើតជម្លោះវិវាទម្តងទៀតរវាងក្រុមហ៊ុន និងប្រជាជនដែលអត់ដី ហើយដែលកំពុងធ្វើចំការក្នុងដីក្រុមហ៊ុន
- ការកើតជម្លោះវិវាទរវាងក្រុមហ៊ុន និងប្រជាជនដែលអត់ដី ហើយដែលអាចចូលរុករានធ្វើចំការក្នុងដីក្រុមហ៊ុន

ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងក្នុងនាមជាអាជ្ញាធរមូលដ្ឋាន ពួកគាត់បានចូលរួមផ្តល់នូវមតិយោបល់ និងសំណូមពរមួយចំនួនដូចខាងក្រោម៖

- សុំដកក្រុមហ៊ុន អេស ខេ ផ្លេនថេសិន នេះចេញពីឃុំប៉ង់ ហើយទុកដីឱ្យប្រជាជនធ្វើស្រែចំការវិញ
- ប្រសិនបើមិនអាចដកចេញ រដ្ឋាភិបាលគួរមានដំណោះស្រាយសមស្រប ចំពោះបញ្ហារឿងវិវាទដីធ្លីដែលនៅសេសសល់នេះ។

➢ កិច្ចពិគ្រោះយោបល់នៅភូមិប៉ុង និងភូមិហ្វាំង

កិច្ចពិភាក្សាជាក្រុមជាមួយមេភូមិ សហគមន៍ និងប្រជាជនភូមិប៉ុង និងភូមិហ្វាំង ត្រូវបានធ្វើឡើងនៅរោងប្រជុំភូមិប៉ុង នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦ ចាប់ពីម៉ោង២:០០រសៀល ដល់ម៉ោង៤:៣០នាទី។ លទ្ធផលនៃកិច្ចពិភាក្សាជាក្រុមបានបង្ហាញថា៖ ប្រជាជនបានដឹងលឺអំពីវត្តមានគម្រោងចាប់តាំងពីក្រុមហ៊ុនចាប់ផ្តើមធ្វើការកំណត់ព្រំដីរបស់ក្រុមហ៊ុន ព្រោះព្រំដីដែលក្រុមហ៊ុនបានកំណត់នេះបានប៉ះក្បាលដីស្រែរបស់ប្រជាជនចំនួន ១០០០ហិកតា។ ប៉ុន្តែក្រុមហ៊ុនបានដោះស្រាយដោយបានកាត់ចេញឱ្យប្រជាជនវិញបានប្រហែល៩០%ហើយ នៅសល់តែប្រមាណ១០%ទៀតដែលនៅមិនទាន់ដោះស្រាយជាស្ថាពរ។ លោកមេភូមិប៉ុងបានបញ្ជាក់ថា បញ្ហាដែលកើតឡើងជាបន្តបន្ទាប់ គឺបណ្តាលមកពីប្រជាជនដែលមានគ្រួសារធំ មានសមាជិកបន្ថែមច្រើនគ្មានដីស្រែសម្រាប់ធ្វើចំការពួកគាត់ត្រូវការរុករានដីថ្មីសម្រាប់ធ្វើចំការ។ ការសាកសួរពីប្រជាជនដែលមានបញ្ហាដីធ្លីទាំងនោះបានបង្ហាញថា នៅក្នុងភូមិប៉ុងមានប្រជាជនប្រហែល៤៥គ្រួសារដែលមិនមានដីចំការហើយបានទៅកាប់រានដីក្រុមហ៊ុនដើម្បីធ្វើស្រែចំការ ដោយសារក្រុមហ៊ុននេះមិនទាន់មានដំណើរការសកម្មភាពអ្វីនៅឡើយ។ ចំពោះភូមិហ្វាំងវិញមានប្រជាជនប្រហែល៥៨គ្រួសារដែលមិនមានដីចំការហើយបានទៅកាប់រានដីរបស់ក្រុមហ៊ុន ដោយពួកគាត់បានអះអាងថាដីទាំងនេះជាដីកេរ្តិ៍ដំណែលរបស់ពួកគាត់ (ប៉ុន្តែពួកគាត់មិនមានប្លង់កម្មសិទ្ធិទេ)។

បន្ថែមពីលើបញ្ហាដីពាក់ព័ន្ធ និងកង្វះខាតដីសម្រាប់ប្រជាជនធ្វើស្រែធ្វើចំការ ប្រជាជនដែលមានបញ្ហាដីស្រែពាក់ព័ន្ធនឹងដីក្រុមហ៊ុនទាំងនេះបានបង្ហាញនូវក្តីបារម្ភមួយចំនួនទៀតដូចខាងក្រោម៖

- ខ្លាចមានគ្រោះធម្មជាតិដូចជា ភ្លើងឆេះព្រៃដោយសារកម្តៅឡើងខ្លាំង ខ្យល់ព្យុះ និងទឹកជំនន់ ព្រមទាំងខ្លាចមានបម្រែបម្រួលប្រភពទឹកអូរធម្មជាតិ និងបាត់បង់គុណភាពដីដោយសារការហូរច្រោះខ្លាំងជាងមុន នៅពេលព្រៃឈើត្រូវបានបាត់បង់ដោយសារសកម្មភាពរបស់គម្រោង
- ការប្រើប្រាស់ដីគីមី អាចបណ្តាលឱ្យប៉ះពាល់ដល់គុណភាពប្រភពទឹកធម្មជាតិ (អូរ បឹង ត្រពាំង)
- បារម្ភខ្លាចនៅពេលអនាគតនៅពេលក្រុមហ៊ុនប្រមូលផលកៅស៊ូ ក្រុមហ៊ុនបិទផ្លូវចេញចូល និងហាមឃាត់មិនឱ្យប្រជាជនធ្វើដំណើរឆ្លងកាត់ ជាពិសេសប្រជាជនដែលមានចំការស្ថិតនៅក្បែរតំបន់គម្រោង
- គ្មានដីបម្រុងទុកសម្រាប់កូនចៅជំនាន់ក្រោយដូចកាលពីមុនមានគម្រោង
- មានការឈូសឆាយលើដីចំការប្រជាជនដែលកំពុងដាំដុះដែលមិនទាន់មានប្លង់កម្មសិទ្ធិច្បាស់លាស់

ដើម្បីកាត់បន្ថយផលប៉ះពាល់ ប្រជាជនដែលចូលរួមក្នុងកិច្ចពិភាក្សាបានលើកឡើងនូវសំណូមពរមួយចំនួនដូចខាងក្រោម៖

- សូមឱ្យក្រុមហ៊ុនកាត់ដីជូនប្រជាពលរដ្ឋដែលគ្មានដីធ្វើស្រែចំការទាំង៥៨គ្រួសារនៅភូមិហ្វាំង និង៤៥គ្រួសារនៅភូមិប៉ុង